សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់និងសោភ័ណភាព ខណ្ឌចំការមន

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨


រៀបរៀងដោយ

និស្សិតឈ្មោះ៖ **កញ្ញា ហុង ដានេ**

**កញ្ញា លី សុជាតា**

សាស្ត្រាចារ្យណែនាំ៖

**បណ្ឌិត ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **ហុង ដានេ** និង **លី សុជាតា** ជានិស្សិតនីតិសាស្រ្តជំនាន់ទី ១៨ នៃសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។

យើងខ្ញុំទាំងពីរ សូមអោនកាយគោរពធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាដោយផ្តល់ភាពកក់ក្តៅ សេចក្តីស្រលាញ់ មេត្តា ករុណា និង អប់រំទូន្មានប្រៀនប្រដៅកូនប្រកប ដោយព្រហ្មវិហារធមិ ឱ្យកូនប្រព្រឹត្តខ្លួនតាមគន្លងល្អៗ ដើម្បីរស់នៅក្នុងសង្គម ព្រមទាំងការទំនុកបំរុងខាងស្មារតី និងឧបត្ថម្ភជាថវិការ សំភារៈ ដល់ការរៀនសូត្រតាំងពីមត្តេយ្យសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រ ។

យើងខ្ញុំទាំងពីររូប សូមធ្វើថ្លែងអំណរគុណបំផុតចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** ដែលបានផ្តល់លទ្ធភាពឲ្យយើងខ្ញុំបានបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងជាពិសេសបានផ្តល់ឱកាសដល់យើងខ្ញុំទាំងពីររូប អាចចូលរួមសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ហើយយើងខ្ញុំទាំងពីរ ក៏សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសាស្រ្តាចារ្យ **ហាប់ ផល្លី** ដែលលោកគ្រូ បានចំណាយពេលយ៉ាងមានតម្លៃខិតខំពន្យល់ ណែនាំ ចែករំលែកបទពិសោធន៍ល្អៗ ជួយកែសម្រួលអក្ខរាវិរុទ្ធ និងការប្រើប្រាស់ពាក្យពេចន៍យ៉ាងច្រើននៅក្នុងអត្ថបទនេះ ដើម្បីជួយជំរុញឲ្យសារណារបស់យើងខ្ញុំទាំងពីររូបសម្រេចបានជាលទ្ធផល។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីររូប សូមគោរពជូនពរចំពោះថ្នាក់ដឹកនាំ បុគ្គលិក និងសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ឲ្យមានសុខភាពល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ចជានិរន្តរ៍។

# អារម្ភកថា

អស់រយៈពេល៤ឆ្នាំ ដែលយើងខ្ញុំទាំងពីរនាក់បានចូលមកសិក្សានៅក្នុង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ។ នៅក្នុងសាកលវិទ្យាល័យនេះ គឺពិតជាសាកលវិទ្យាល័យមួយដ៏គួរឲ្យចាប់អារម្មណ៍ ព្រោះសំបូរទៅដោយសាស្ត្រាចារ្យល្បីៗ ដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន និងណែនាំសិស្សនិស្សិតឲ្យយល់ច្បាស់ពីជំនាញ ដែលសិស្សនិស្សិតបានជ្រើសរើសយកមកសិក្សា ក្នុងនោះដែរ ចំពោះជំនាញដែលយើងខ្ញុំទាំងពីរ បានជ្រើសរើសយកមកសិក្សានោះ គឺជំនាញផ្នែកនីតិសាស្ត្រ។

ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរពិតជាមានក្តីសោមនស្សរីករាយជាខ្លាំង ដោយយើងខ្ញុំទាំងពីរនាក់ទទួលបាននូវចំនេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី និង ការអនុវត្តនៅក្នុងផ្នែកនេះ។ ដោយចំណេះដឹងដែលទទួលបាននេះហើយ ក៏បានជំរុញឱ្យ ពួកយើងខ្ញុំធ្វើការសម្រេចចិត្តជ្រើសរើសយកការសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ដោយជ្រើសរើសយកប្រធានបទ "**ការរៀបចំសណ្តាប់ធ្នាប់និងសោភ័ណភាពខណ្ឌចំការមន**" នេះមកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវ ដើម្បីធ្វើជាជំនួយស្មារតី ក៏ដូចជាឯកសារសិក្សាបន្ថែមសម្រាប់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកដែលចង់ស្វែងយល់ពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ខណ្ឌចំការមន ។

យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ គឺនៅមានចំនុចខ្វះចន្លោះ ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យដូចនេះសូម លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេតាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំផង ហើយក្រុមយើងខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ក្នុងការទទួលនូវយកការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះអោយមានភាពល្អប្រសើរ។

*សូមអរ*

*គុណ!*

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១៖ ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌចំការមន**

**១.១. ទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ** ........................................ ៣

**១.១.១.កត្តាដែលនាំឱ្យមានការរៀបចំខណ្ឌចំការមនឱ្យមានសណ្តាប់ធ្នាប់** ........ ៥

១.១.១.១.កត្តាកំណើនប្រជាជន ........................................ ៦

១.១.១.២.កត្តាចរាចរណ៍ ........................................ ៦

១.១.១.៣.កត្តាសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ........................................៧

**១.១.២.រចនាសម្ព័ន្ធខណ្ឌចំការមន** ........................................៧

**១.២. ទិដ្ឋភាពគតិយុត្តិនៃការរៀបចំខណ្ឌ និងទិសដៅអភិវឌ្ឍក្នុងខណ្ឌនាពេលអនាគត** ... ៩

**១.២.១.បច្ចុប្បន្នភាពនៃការរៀបចំខណ្ឌចំការមន**........................................ ៩

១.២.១.១.ស្ថានភាពសេដ្ឋកិច្ចក្នុងខណ្ឌចំការមន ........................................១០

១.២.១.១.១.ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់........................................ ១០

១.២.១.១.២.សិប្បកម្ម ឧស្សាហកម្មធុនតូច និងមធ្យម........................................ ១១

១.២.១.២.ស្ថានភាពសង្គមកិច្ចក្នុងខណ្ឌចំការមន ........................................១២

១.២.១.២.១.ការងារអប់រំ ........................................១២

១.២.១.២.២.ការងារសុខាភិបាល ........................................ ១៣

១.២.១.៣.ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ..................... ១៣

១.២.១.៣.១.ការងារគ្រប់គ្រងដីធ្លី និងសំណង់ ........................................ ១៣

១.២.១.៣.២.ការងារបរិស្ថាន ........................................១៤

១.២.២.ទិសដៅនិងយុទ្ធសាស្ត្រអភិវឌ្ឍក្នុងខណ្ឌចំការមននាពេលអនាគត........................................ ១៥

១.២.២.១.ផ្នែកសេដ្ឋកិច្ច ............................................................ ១៥
១.២.២.២.ផ្នែកសង្គមកិច្ច ............................................................ ១៥
១.២.២.៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន ............................................................ ១៥
១.២.២.៤.ផ្នែករដ្ឋបាល និងសន្តិសុខ ............................................................ ១៦

## ជំពូកទី២៖ សោភ័ណភាពក្នុងខណ្ឌចំការមន

**២.១. ហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន និងយន្តការក្នុងការរៀបចំសោភ័ណភាពក្នុងខណ្ឌចំការមន** ............................................................ ១៧

**២.១.១. ហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន** ............................................................ ១៧
២.១.១.១. ហេតុបង្កនាំឱ្យមានការបំពុលទឹក ដី និងខ្យល់ ............................................................ ១៨
២.១.១.១.១. ហេតុបង្កនាំឱ្យមានការបំពុលទឹក ............................................................ ១៨
២.១.១.១.២. ហេតុបង្កនាំឱ្យមានការបំពុលដី ............................................................ ២០
២.១.១.១.៣. ហេតុបង្កនាំឱ្យមានការបំពុលខ្យល់ ............................................................ ២១
២.១.១.២. ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់រឹង រាវ និងសំឡេង ............................................................ ២៤
២.១.១.២.១. ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់រឹង ............................................................ ២៤
២.១.១.២.២. ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់រាវ ............................................................ ២៦
២.១.១.២.៣. ហេតុបង្កនាំឱ្យមានការបំពុលដោយសំឡេង ............................................................ ២៧

**២.១.២. យន្តការក្នុងការរៀបចំសោភ័ណភាពក្នុងខណ្ឌចំការមន** ............................................................ ២៩
២.១.២.១. ការរៀបចំបណ្តាញខៀវ និងបណ្តាញបៃតង ............................................................ ២៩
២.១.២.១.១. បណ្តាញខៀវ ............................................................ ២៩
២.១.២.១.២. បណ្តាញបៃតង ............................................................ ២៩
២.១.២.២. វិធានការការពារ និងបញ្ហាប្រឈមក្នុងការអភិវឌ្ឍបរិស្ថាន ............................................................ ៣០
២.១.២.២.១.វិធានការការពារទាក់ទងនឹងបរិស្ថាន ............................................................ ៣០
២.១.២.២.២. បញ្ហាប្រឈមក្នុងការអភិវឌ្ឍបរិស្ថាន ............................................................ ៣១

**២.២. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលបរិស្ថាន** .................................. ៣១

**២.២.១. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលទឹក ដី និងខ្យល់** ........................ ៣២

២.២.១.១. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលទឹក................................................... ៣២

២.២.១.២. វិធានការដោះស្រាយចំពោះការបំពុលដី .............................................................៣៣

២.២.១.៣. វិធានការដោះស្រាយចំពោះការបំពុលខ្យល់ .......................................................៣៣

**២.២.២. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលដោយសំណល់រឹងរាវ និងសំឡេង** ... ៣៤

២.២.២.១.វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលដោយសំណល់រឹងរាវ ............................. ៣៤

២.២.២.១.១. សំណល់រឹង ......................................................................................... ៣៥

២.២.២.១.២. សំណល់រាវ ......................................................................................... ៣៦

២.២.២.២. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលដោយសំឡេង .....................................៣៧

**សេចក្ដីសន្និដ្ឋាន** ........................................................................................... ៣៨

**អនុសាសន៍**........................................................................................................ ៣៩

**គន្ថនិទ្ទេស**

# សេចក្តីផ្តើម

ក្រោយពីបានឆ្លងកាត់សង្គ្រាមស៊ីវិលអស់ជាច្រើនទសវត្សន៍មក ព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយមួយ ក្នុងកិច្ចការស្តា និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ។

បើធ្វើការប្រៀបធៀប រាជធានីភ្នំពេញបច្ចុប្បន្ននេះ ទៅនឹងអតីតកាល គឺនឹងឃើញថាទាំងវិស័យ

កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ពិសេសវិស័យនគរូបនីយកម្ម គឺមានការរីកចម្រើនខ្លាំងគួរឱ្យកត់សម្គាល់ ។រីឯនៅតាមដងផ្លូវមាននូវសំណង់អគារធំៗ ខ្ពស់ៗជាច្រើនបាននឹងកំពុងលេចរូបរាងឡើងជាបន្តបន្ទាប់ ។ ក្រៅពីនេះក៏មានការសាងសង់ ស្ពាន ស្ថាប័នរដ្ឋនិងឯកជន ការជួសជុលស្តារប្រព័ន្ធលូ ផ្លូវថ្នល់ក៏មានក្រាលកៅស៊ូ និងស៊ីម៉ង់ត៍ ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរផងដែរ។

ប្រទេសកម្ពុជាសព្វថ្ងៃ បើប្រៀបធៀបទៅនឹងអតីតកាល គឺឃើញថាមានការអភិវឌ្ឍជាងមុន តែបើប្រៀបធៀបជាមួយបណ្តាប្រទេសជិតខាងដូចជាថៃ វៀតណាមជាដើមនោះ កម្ពុជានៅមានភាពខ្វះចន្លោះនៅឡើយ ហើយជាការទាមទារឱ្យមានការអភិវឌ្ឍបន្ថែម។ ទន្ទឹមនឹងការអភិវឌ្ឍនេះក៏មាននូវជាបញ្ហាចោទឡើងមួយចំនួនពាក់ព័ន្ធនឹងបញ្ហាសណ្តាប់ធ្នាប់ សោភ័ណភាពផងដែរ។

ចំណែកគោលបំណងនៃការស្រាវជ្រាវពាក់ព័ន្ធនឹងប្រធានបទ "ការរៀបចំខណ្ឌចំការមនឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព"វិញ គឺដោយសារ ទីមួយចង់យល់ដឹងបន្ថែមពីបច្ចុប្បន្នភាព និងដំណើរការប្រព្រឹត្តទៅក្នុងការរៀបចំខណ្ឌឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព និង ទីពីរគឺវិធានការការពារនិងបញ្ហាប្រឈមក្នុងការអភិវឌ្ឍបរិស្ថានក្នុងខណ្ឌ។

នៅក្នុងប្រធានបទសារណានេះនឹងធ្វើការបែងចែកជា២ជំពូក។ ជំពូកទី១ បង្ហាញពីទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ និងទិដ្ឋភាពគតិយុត្តិនៃការរៀបចំខណ្ឌចំការមន។ រីឯជំពូកទី២ លើកឡើងពីហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន និងយន្តការក្នុងការរៀបចំសោភ័ណភាពក្នុងខណ្ឌចំការមន និង វិធានការគតិយុត្តិដោះស្រាយចំពោះការបំពុលបរិស្ថាន។

## ជំពូកទី១៖ ការរៀបចំសណ្ដាប់ធ្នាប់ខណ្ឌចំការមន

មុននឹងឈានចូលដល់ការរៀបរាប់ពីការអភិវឌ្ឍ និងការរៀបចំក្នុងខណ្ឌចំការមន ដំបូងគួរស្វែងយល់ពីប្រវត្តិខ្លះៗនៃការរៀបចំក្រុងដំបូងគេបង្អស់នៅលើសកលលោកជាមុនសិន។ ចំពោះការរៀបចំទីក្រុងដំបូងគេបង្អស់នេះ គឺមានការលើកឡើងពីមជ្ឈដ្ឋានផ្សេងៗគ្នា។ នៅក្នុងនោះមតិទីមួយលើកឡើងថាទីក្រុងចំណាស់ជាងគេ គឺទីក្រុង Damascus នៃប្រទេសស៊ីរី និងមតិទីពីរថាជាទីក្រុង Faiyum ប្រទេសអេហ្ស៊ីប ។

ចំពោះការលើកឡើងទីមួយគឺ ទីក្រុង Damascus នៃប្រទេសស៊ីរី ដែលត្រូវបានមនុស្សលើសកលលោកជឿថាជាទីក្រុងចំណាស់បំផុត ដែលបន្តវត្តមាននៅលើផែនដីមកទល់នឹងបច្ចុប្បន្ន។ ភស្តុតាងជាច្រើនត្រូវបុរាណវិទូលើពិភពលោករកឃើញជាបន្ទាប់ និងអះអាងថាជាទីក្រុងមានអាយុកាលយ៉ាងហោចណាស់ ៨,០០០ ដល់ ១០,០០០ឆ្នាំមុនគ្រឹស្តសករាជ ស្ថិតក្នុងភាគខាងត្បូងឆៀងខាងលិចប្រទេសស៊ីរី។ ទីក្រុងនេះមានផ្ទៃក្រឡាសរុប ១០៥ គីឡូម៉ែត្រការ៉េ ជាទីក្រុងធំបំផុតក្នុងប្រទេសស៊ីរីធ្លាប់មានឈ្មោះជាអារ៉ាប់ថាទីក្រុងផ្កាម្លិះ ហើយកាលពីឆ្នាំ២០០៨ ត្រូវបានប្រកាសជារដ្ឋធានីនៃវប្បធម៌ពិភពអារ៉ាប់ទាំងមូលតែម្តង។[1]

ចំពោះការរៀបចំក្រុងវិញ ដោយសារទីក្រុង Damascus មានភូមិសាស្ត្រអំណោយផលបានក្លាយជាតំបន់វប្បធម៌ និងពាណិជ្ជកម្មសំខាន់ ពីតំបន់អាស៊ី ទៅបស្ចឹមប្រទេស។ តាមការស្រាវជ្រាវគេបានរកឃើញថា ទីក្រុង Damascus នៅសម័យនោះគឺមានស្ថាបនា ផ្សារ សំណង់ អគារដូចជាវិហារសាសនាធំៗជាច្រើន និងមន្ទីរពេទ្យដែលធ្វើឡើងតាមបែបបទរ៉ូម៉ាំងជាដើម។[2]

រីឯការលើកឡើងមួយវិញទៀត ទីក្រុងចំណាស់ជាងគេ គឺទីក្រុង Faiyum និង ត្រូវបានរកឃើញនៅអំឡុង ៤០០០ឆ្នាំមុនគ.ស ជាទីក្រុងដែលចាស់ជាងគេបំផុតនៅប្រទេសអេហ្ស៊ីប។ ទីក្រុងនេះត្រូវបានគេរកឃើញថាមានផ្សារធំៗជាច្រើនកន្លែងងូតទឹកនិងវិហារឥស្លាមជាដើម។ លើសពីនេះ ក៏មាននូវប្រឡាយទឹកមួយគេហៅថា Bahr Yussef ហូរតាមបណ្តោយទីក្រុង និងមានផ្ទះជាច្រើនសង់ជាជួរនៅតាមច្រាំងទន្លេ ព្រមទាំងមានស្ពានពីរកាត់ទន្លេមួយក្នុងចំណោមនោះតភ្ជាប់ពីផ្លូវធំទៅ

[1] ចូលមើលលើកចុងក្រោយ ១៩ មេសា ២០១៨ https://theculturetrip.com/middle-east/lebanon/articles/the-10-oldest-cities-in-the-world/ ។

[2] ចូលមើលលើកចុងក្រោយ ២០ មេសា ២០១៨http://islamic-arts.org/2011/damascus-history-arts-and-architecture/។

កាន់ផ្សារនៅក្នុងក្រុង។ ជនជាតិក្រិក នៅសម័យនោះបង្ហាញអំពីការគោរពបូជាសត្វក្រពើ ហើយរក្សានូវបឹង Moeris ជាទីសក្ការ។ រីឯចំកណ្តាលទីក្រុង គឺមានកសាងនូវប្រឡាយទឹកដែលមានរហាត់ទឹកចំនួន៤ជាតំណាងនិមិត្តសញ្ញាជាតិ ។[3]

## ១.១. ទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ

តាមប្រវត្តិពង្សាវតាខ្មែរ ប្រភពដើមរបស់ឈ្មោះរាជធានីភ្នំពេញត្រូវបានបង្កើតឡើង និងរកឃើញដោយលោកយាយពេញ នៅក្នុងឆ្នាំ១៣៧២ ដោយមានឈ្មោះថា វត្តភ្នំដូនពេញ ដែលមកដល់សព្វថ្ងៃត្រូវគេហៅកាត់ថា វត្តភ្នំ។ ចំពោះការបង្កើតរាជធានីភ្នំពេញវិញ ត្រូវបានសាងសង់ជាលើកដំបូង នៅក្នុងសតវត្សរ៍ទី១៥ ក្នុងអំឡុងរជ្ជកាលព្រះបាទស្រីសុរិយោព័រ(ពញាយ៉ាត) និងលើកទី២ ក្នុងរជ្ជកាលព្រះបាទនរោត្តមក្នុងសតវត្សរ៍ទី ១៩ ទើបបិតបេរមកដល់សព្វថ្ងៃ។[4] មុនសម័យខ្មែរក្រហម គេសង្កេតឃើញថា រាជធានីភ្នំពេញមានការរីកចម្រើនខ្លាំង ពិសេសសម័យសង្គមរាស្ត្រនិយមតែម្តង ប៉ុន្តែគួរឱ្យសោកស្តាយការរីកចម្រើននេះមិនបានស្ថិតស្ថេររហូតនោះទេ។ នៅថ្ងៃទី ១៧ មេសា ១៩៧៥ គឺជាថ្ងៃដែលប្រទេសកម្ពុជាទាំងមូល និងប្រជាជនកម្ពុជាបានធ្លាក់ចូលក្នុងរបបខ្មៅងងឹតគឺរបបកម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយ ប៉ុល ពត។ នាសម័យនោះកម្ពុជា ត្រូវបានប្រែប្រួលទាំងស្រុង ដោយពួកខ្មែរក្រហមបានធ្វើការលុបបំបាត់រូបិយវត្ថុ ការអប់រំ ទ្រព្យសម្បត្តិឯកជន ម៉ូតសម្លៀកបំពាក់ស៊ីវិលពីបរទេស ការគោរពជំនឿសាសនា និងប្រពៃណីវប្បធម៌ខ្មែរ។

សាលារៀន វត្តអារាម វិហារសាសនា សាកលវិទ្យាល័យ ហាងទំនិញ និងអគាររដ្ឋាភិបាល ត្រូវបានបិទទ្វារ ឬក៏ប្រែក្លាយទៅជាគុក ក្រោលគោ ជំរំអប់រំកែប្រែ និងជង្រុកស្រូវ។[5] ពេលនោះរាជធានីភ្នំពេញ ត្រូវបានគេឲ្យឈ្មោះថាជាទីក្រុងខ្មោចដោយសារតែគ្មានពលរដ្ឋណារស់នៅ ក្រៅតែពីកម្មាភិបាលខ្មែរក្រហម កងទ័ព និងកម្មករប្រមាណ ៤ពាន់នាក់ប៉ុណ្ណោះ។[6] ទោះបីជាយ៉ាងណាក៏ដោយ របបគ្រប់គ្រងដ៏យង់ឃ្នងនេះ មិនបាននៅស្ថិតស្ថេរយូរអង្វែងនោះទេ ដោយរបបនេះត្រូវបានដួលរលំទៅវិញនៅថ្ងៃទី ០៧ មករា ១៩៧៩ដែលជាថ្ងៃដែលទីក្រុងភ្នំពេញត្រូវរំដោះបានទាំងស្រុងនិងជាថ្ងៃបើកទំព័រថ្មីនៃប្រវត្តិសាស្ត្រ។

[3] អ៊ុន សកក្កដា, "នីតិនគរូបនីយវិទ្យា" (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ១។

[4] ចូលមើលលើកចុងក្រោយ ២១ មេសា ២០១៨http://phnompenh.gov.kh/phnom-penh-city/history ។

[5] ចូលមើលលើកចុងក្រោយ ២១ មេសា ២០១៨https://www.slideshare.net/khmer-sacrifice/1975-1979 ។

[6] ចូលមើលលើកចុងក្រោយ ២១ មេសា ២០១៨https://www.rfa.org/khmer/multimedia/after-khmer-rouge-11092017202904.html ។

ក្រោយពីថ្ងៃរំដោះ ដោយសារប្រទេសទើបតែងើបរួចពីសង្គ្រាម ទីក្រុងភ្នំពេញ និងបណ្ដាខេត្តនានា ក្នុងប្រទេសទាំងមូលទទួលរងនូវការបំផ្លាញខ្ទេចខ្ទី ដែលធ្វើឱ្យប្រជាជនរស់នៅក្នុងសភាពលំបាកលំបិនជាខ្លាំង។ បញ្ហាដែលចោទឡើង ក្រោយការវាយរំលំរបប ប៉ុល ពត មានជាច្រើនឥតគណនា។ ក្រៅពីការកសាង ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និងវប្បធម៌ឡើងវិញដោយចាប់ផ្ដើមពីសូន្យ របបថ្មីត្រូវធ្វើឱ្យប្រជាជនដែលនៅសល់ពីការសម្លាប់រង្គាលក្នុងរបប ប៉ុល ពត រស់រានមានជីវិតឡើងវិញ។[7] ភារកិច្ចបន្ទាន់បំផុត បានចោទមានឡើងចំពោះសង្គមជាតិ នាសម័យនោះ គឺ សេចក្ដីអត់ឃ្លាន ការខ្វះខាតស្បៀងអាហារ ខ្វះថ្នាំព្យាបាល។ល។ ដែលក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាត្រូវតែតស៊ូជំនះឱ្យខាងតែបាន។[8]

ក្នុងសភាពការណ៍ដ៏តានតឹងនេះ ប្រទេសកម្ពុជាក៏បានទទួលជំនួយពីបណ្ដាប្រទេសផ្សេងៗ ដែលមានជាស្បៀងអាហារ សម្ភារៈប្រើប្រាស់ ថ្នាំសង្កូវ ឧបករណ៍ផលិតកម្ម វត្ថុធាតុដើម ដែលជាជំនួយក្នុងការចាប់ផ្ដើមនូវសកម្មភាពផលិតកម្មឧស្សាហកម្ម សិប្បកម្ម កសិកម្ម ដែលជាជំហានដំបូងនៃជីវិតសេដ្ឋកិច្ចសង្គម។[9] ចូលដល់ឆ្នាំ១៩៨០ កម្ពុជាក៏ទទួលបានជំនួយបន្ថែមទៀត ហើយក៏បានចាប់ផ្ដើមស្តារ និងកសាងសង្គមមួយដែលគ្មានហេដ្ឋារចនាសម្ព័ន្ធខាងសេដ្ឋកិច្ច និងគ្មានហេដ្ឋារចនាសម្ព័ន្ធសង្គមទាំងមូល ឱ្យមានភាពប្រសើរឡើងជាបណ្ដើរៗ ក្នុងនោះវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ពាណិជ្ជកម្ម គមនាគមន៍ និងសំណង់ ត្រូវបានគេយកចិត្តទុកដាក់ជាខ្លាំង ហើយប្រជាជន និងរដ្ឋអំណាចបានសហការគ្នាជំនះរាល់ការលំបាកគ្រប់បែបយ៉ាង និងបានកែប្រែសោភ័ណភាព សណ្ដាប់ធ្នាប់ សន្តិសុខ រាជធានីភ្នំពេញដើម្បីឆ្ពោះទៅរកការរីកចម្រើនដូចបណ្ដាប្រទេសដទៃៗទៀតក្នុងតំបន់។

ភ្នំពេញ ស្ថិតនៅក្នុងតំបន់ខាងត្បូង-កណ្ដាលនៃប្រទេសកម្ពុជា នៅចំណុច ប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ។ទន្លេទាំងនេះផ្ដល់នូវ ប្រព័ន្ធអេកូឡូស៊ីទឹកសាបនិងទន្លេប្រកបដោយសក្ដានុពលជាធនធានដ៏សំខាន់សម្រាប់លក្ខខណ្ឌបរិស្ថានប្រកបដោយចិរភាព សោភ័ណភាពធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុងចម្រើនសម្រាប់ប្រជាជននៅរាជធានី ភ្នំពេញតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។[10]

---

[7] វ៉ាន់ឌី កាអុន, *សុបិន និងការពិត* (ភ្នំពេញ៖ សមាគមកម្ពុជា-អាស៊ី, ២០១២), ២៖ ១០៨។

[8] ឈុន ពហុ, *ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប)* (ភ្នំពេញ, ២០០៤), ១។

[9] ឈុន ពហុ, *ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប)* (ភ្នំពេញ, ២០០៤, ៣។

[10] ចូលមើលលើកចុងក្រោយ ២១ មេសា ២០១៨http://phnompenh.gov.kh/phnom-penh-city/facts/។

ភ្នំពេញជារាជធានី និងជាទីក្រុងធំជាងគេបំផុតនៃប្រទេសកម្ពុជាជាមជ្ឈមណ្ឌលសន្តិសុខ នយោបាយ សេដ្ឋកិច្ច សម្បត្តិវប្បធម៌ និងការទូត។ បច្ចុប្បន្នរាជធានីភ្នំពេញមានផ្ទៃដីសរុប៦៧៨,៤៦ គីឡូម៉ែត្រក្រឡា ដែលមានប្រជាជនសរុប ១,៤៩៥,៨៨៨ នាក់ក្នុងឆ្នាំ២០១៤ ដែលត្រូវជា ២៧៨,៧៥២ គ្រួសារ មានដង់ស៊ីតេមនុស្សរស់នៅ ២,១៣២ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ ចំណែក ខណ្ឌនៅក្នុងរាជធានីភ្នំពេញវិញ ត្រូវបានបែងចែកជា ១២ខណ្ឌ ៩៦សង្កាត់ ៩០៩ភូមិ។[11]

ខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញមានដូចជា៖ ខណ្ឌដូនពេញ ខណ្ឌមានជ័យ ខណ្ឌទួលគោក ខណ្ឌដង្កោ ខណ្ឌ៧មករា ខណ្ឌចំការមន ខណ្ឌពោធិ៍សែនជ័យ ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌព្រែកព្នៅ ខណ្ឌជ្រោយចង្វា ខណ្ឌច្បារអំពៅ។

ចំពោះវិសាលភាពនៃការស្រាវជ្រាវគ្របដណ្តប់តែចំពោះក្នុងខណ្ឌចំការមនមួយតែប៉ុណ្ណោះ។

### ១.១.១.កត្តាដែលនាំឱ្យមានការរៀបចំខណ្ឌចំការមនឱ្យមានសណ្តាប់ធ្នាប់

ដើម្បីងាយស្រួលក្នុងការកំណត់ន័យនៃអត្ថបទទាំងមូល ការយល់ពីអត្ថន័យនៃពាក្យមួយចំនួនជាការចាំបាច់។ "សណ្តាប់ធ្នាប់ រួមមានធាតុសំខាន់៣ គឺ សន្តិសុខ ភាពស្ងប់ស្ងៀម និងភាពអនាម័យ។ សន្តិសុខ សំដៅលើការមិនបានប៉ះពាល់បូរណភាពរូបកាយ និងផ្លូវចិត្ត។ ភាពស្ងប់ស្ងៀម សំដៅលើការមិនរំខានដោយសំឡេង ដូចជាការចាក់ភ្លេង ធុងបាស ការបំពងសំឡេងក្នុងកម្មវិធីនានា ការឃោសនា និងភាពអនាម័យសំដៅលើការមិនប៉ះដល់សុខភាព និងសុខុមាលភាពដូចជាក្លិនកខ្វក់សំរាមប្រព័ន្ធលូបង្កន់អនាម័យ ជំងឺឆ្លង" ។[12] រីឯសោភ័ណភាពមានន័យថា ល្អ ហ្មត់ហ្មង។[13]

ចំពោះបុព្វហេតុដែលនាំឱ្យមានការរៀបចំខណ្ឌចំការមននេះ គឺដោយសារខណ្ឌចំការមនជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង ១២ របស់រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ មានប្រទល់ខាងកើតជាប់នឹងខណ្ឌច្បារអំពៅ ខណ្ឌដាច់ដោយដងទន្លេបាសាក់ ខាងលិចជាប់នឹងខណ្ឌទួលគោក ខាងត្បូងជាប់នឹងខណ្ឌមានជ័យ ខាងជើងជាប់នឹងខណ្ឌ៧មករា និងខណ្ឌដូនពេញ។

ខណ្ឌចំការមនបានបែងចែកជា ១២សង្កាត់ ៩២ភូមិមានផ្ទៃដីសរុបចំនួន ១០.៥៣០ គីឡូម៉ែត្រក្រឡា មាន ២០,០១១គ្រួសារ រស់នៅ ស្មើនឹងប្រជាជនចំនួន ១០៦,៧៥១

---

[11] ព្រឹត្តិបត្ររដ្ឋបាលរាជធានីភ្នំពេញលេខ១៨ ខែមេសា ឆ្នាំ២០១៦, ៩៥។

[12] សាស្ត្រាចារ្យបណ្ឌិត ថេង ច័ន្ទសង្វារ, *នីតិរដ្ឋបាលទូទៅ,* រៀបរៀងដោយ ជួប ប៊ិតបេរឬទ្ធិ, (ភ្នំពេញ៖ ២០១២-២០១៣), ៣៥។

[13] ជួន ណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ ១៩៦៧), ១០៦២ ។

នាក់ ក្នុងនោះស្ត្រីមានចំនួន៥៤,៤៧៧នាក់ គិតជាដង់ស៊ីតេប្រជាជនស្មើនឹង ១០,១៣៧.៧៩ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា។[14]

ក្នុងខណ្ឌចំការមនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដែលបង្កភាពងាយស្រួលដល់ប្រជាជនរស់នៅប្រចាំថ្ងៃ។ តែបើទោះជាយ៉ាងណាក៏ដោយ ក៏នៅតែត្រូវការអភិវឌ្ឍបន្ថែម ដើម្បីឱ្យកាន់តែភាពសំបូរបែប ហើយកត្តាជំរុញឱ្យមានការអភិវឌ្ឍបន្ថែមទៀតនោះគឺៈ

**១.១.១.១.កត្តាកំណើនប្រជាជន**

បញ្ហាកំណើនប្រជាជនជាបញ្ហាចំបងមួយដែលកើតមានឡើង មិនមែនមានតែកម្ពុជាទេសូម្បីបណ្តាប្រទេសផ្សេងៗទាំងតំបន់អាស៊ី និងអឺរ៉ុបសុទ្ធតែបានជួបនូវបញ្ហានេះ។ ដោយសារកំណើនប្រជាជនកើតមានរាល់ថ្ងៃជាលក្ខណៈធម្មជាតិផង កំណើនដោយសារចំណាកស្រុកផង និងកំណើនដោយសារតែការបែងចែកសណ្ឋានដីនៃក្រុងថ្មីផងនោះ ក៏បានធ្វើឱ្យទីក្រុងក្លាយជាតំបន់សំបូរមនុស្សរស់នៅច្រើន។ បើធ្វើការប្រៀបធៀបចំនួនប្រជាជននៅឆ្នាំ២០១៦ និង ២០១៧នោះនឹងឃើញថាមានប្រជាជនសរុបក្នុងឆ្នាំ២០១៦ មានត្រឹម ១៥,៧៦២,៣៧០នាក់ប៉ុណ្ណោះ ប៉ុន្តែទិន្នន័យនេះមានការប្រែប្រួលដល់ ១៦,០០៥,៣៧៣ នាក់ក្នុងឆ្នាំ២០១៧។[15] ដោយមានការកើនឡើងនូវកំណើនប្រជាជនជារៀងរាល់ថ្ងៃបែបនេះហើយ ទើបធ្វើឱ្យទីក្រុងមានភាពចង្អៀតកកស្ទះ។ ដោយហេតុនេះហើយ ដើម្បីដោះស្រាយបញ្ហាទាំងនេះបាន គឺទាមទារឱ្យមានការអភិវឌ្ឍ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសង្គម ពីព្រោះកាលណាប្រជាជនកាន់តែមានកំណើនតម្រូវការក៏មានការកើនឡើងស្របជាមួយគ្នាដែរ។

**១.១.១.២.កត្តាចរាចរណ៍**

កត្តាចរាចរណ៍ គឺជាកត្តាមួយដែលនាំឱ្យមានការអភិវឌ្ឍ ហើយកត្តាចរាចរណ៍នេះផ្ទាល់គឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិជាមួយកត្តាទីមួយ កំណើនប្រជាជន។ កាលណាប្រជាជនមានកំណើនខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ នោះការប្រើប្រាស់នូវយានជំនិះក៏ឃើញថាមានការកើនឡើងស្របគ្នាដែរ។

បច្ចុប្បន្នបញ្ហាកកស្ទះចរាចរណ៍ កំពុងក្លាយជាកង្វល់យ៉ាងខ្លាំងសម្រាប់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ក៏ចំនួននៃអ្នកប្រើប្រាស់រថយន្ត

[14] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ ២០១៨-២០២០, V។

[15] ចូលមើលលើកចុងក្រោយ ២២ មេសា ២០១៨http://www.worldometers.info/world-population/cambodia-population/ ។

និងម៉ូតូហាក់មិនថមថយសោះ ខណៈដែលចំនួនប្រជាជនមកតាំងទីរស់នៅ និងធ្វើការនៅរាជធានីមួយនេះចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ជាក់ស្តែង ក្នុងឆ្នាំ២០១៦កន្លងទៅចំនួនយានយន្តដែលបានចុះបញ្ជីត្រឹមត្រូវ និងកំពុងចរាចរនៅរាជធានីភ្នំពេញមានរថយន្ត សរុបចំនួន ៨៤២,៩៧២គ្រឿង និង ម៉ូតូសរុបចំនួន ១,៦០១,៨៥១គ្រឿង។[16] ក្រៅពីបញ្ហាការកើនឡើងនៃយានយន្ត ហេដ្ឋារចនាសម្ព័ន្ធផ្លូវក៏ជាបញ្ហាចោទដែលនាំឱ្យមានការកកស្ទះចរាចរណ៍ផងដែរ ដោយសារផ្លូវក្នុងខណ្ឌមានសភាពទ្រុឌទ្រោម និងតូចចង្អៀតពិបាកធ្វើដំណើរ មានជង្ហុក ប្រេះស្រាំ ខ្វះការថែទាំ រថយន្តដឹកទំនិញលើសទម្ងន់ យកផ្លូវថ្នល់ធ្វើចំណតពលរដ្ឋខ្វះចំណេះដឹងពីច្បាប់ចរាចរណ៍ និងពុំទាន់មានភ្លើងបំភ្លឺគ្រប់ផ្លូវ និងច្រកផ្លូវ ដែលកត្តាទាំងនេះហើយ ដែលធ្វើឱ្យប៉ះពាល់ចរាចរនៅក្នុងខណ្ឌ។

**១.១.១.៣.កត្តាសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ**

តាមច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានបែងចែកការគ្រប់គ្រងដែនដី ដោយបានកំណត់ព្រំប្រទល់រដ្ឋបាលខណ្ឌ សង្កាត់ ភូមិច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។[17] បច្ចុប្បន្នរដ្ឋបាលខណ្ឌចំការមន មានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដោយហេតុថាចំនួនករណីឃាតកម្ម ប្លន់ ចាប់ជំរិត មានដល់ ១៨០ករណីក្នុងឆ្នាំ២០១៣ បើធៀបជាមួយឆ្នាំ២០១២ មានតែ ២ករណីប៉ុណ្ណោះ រីឯករណីលួចវិញ ក៏មានការកើនឡើងដូចគ្នា គឺ១៩៨ករណី ក្នុងឆ្នាំ២០១៣ និង ៨៤ករណីក្នុងឆ្នាំ២០១២។[18]

ក្រៅពីនេះបញ្ហាក្មេងទំនើង គ្រឿងញៀន ចរាចរណ៍ គ្រោះអគ្គីភ័យ បញ្ហាដីធ្លី លំនៅដ្ឋានបរិស្ថាន សំរាម និងសណ្តាប់ធ្នាប់តាមដងផ្លូវនៅតែចោទជាបញ្ហា អាស្រ័យដោយកំណើនយ៉ាងឆាប់រហ័ស នៃមធ្យោបាយយានយន្ត និងប្រជាជន ដែលជាហេតុទាមទារឱ្យមានការអភិវឌ្ឍ និងចាត់វិធានការបន្ថែមដើម្បីលើកកម្ពស់ការរស់នៅ និងសុខមាលភាពរបស់ប្រជាជន។

**១.១.២.រចនាសម្ព័ន្ធខណ្ឌចំការមន**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលត្រូវបានជ្រើសរើសឡើង

[16] ចូលមើលលើកចុងក្រោយ ២២ មេសា ២០១៨https://postnews.com.kh/hotnews/120869 ។

[17] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨, មាត្រា៨។

[18] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ២៨។

តាមការបោះឆ្នោតអសកល។[19] ក្រុមប្រឹក្សាមានអាណត្តិ ៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានិងផុត
កំណត់ថ្ងៃបោះឆ្នោតបន្ទាប់។[20] ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ដោយប្រធានក្រុមប្រឹក្សាគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សាប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជនដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជន និងមានសំឡេងឆ្នោតបានការច្រើនជាងគេ។[21]

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើតការជំរុញ និង ការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់។[22] ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជារាស្ត្រ និង កត្តាភូមិសាស្ត្រ។[23]

រចនាសម្ព័ន្ធខណ្ឌចំការមនរួមមាន៖ សមាជិកក្រុមប្រឹក្សាខណ្ឌ ចំនួន១៩នាក់ ស្រី០៤នាក់, ប្រធានក្រុមប្រឹក្សាខណ្ឌ០១នាក់ប្រុស, សមាជិកក្រុមប្រឹក្សាខណ្ឌដែលបានផ្លាស់ប្តូរ គ្មាន, គណៈអភិបាលខណ្ឌមាន០៥នាក់ ស្រី០១នាក់ ក្នុងនោះអភិបាលខណ្ឌ០១ និងអភិបាលរងខណ្ឌ ០៤នាក់ នាយក នាយករង រដ្ឋបាល ០៣នាក់, ប្រធានការិយាល័យ និងអង្គភាពលទ្ធកម្ម ០៥នាក់ ស្រី០១ នាក់អនុប្រធានការិយាល័យនិងអង្គភាពលទ្ធកម្ម ០៤នាក់, មន្ត្រីការិយាល័យ និងស្មៀនសង្កាត់ ចំនួន៤២នាក់ ស្រី១៧នាក់, បុគ្គលិកជាប់កិច្ចសន្យា ១៧៧នាក់ ស្រី៣៦នាក់។[24]

---

[19] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨, មាត្រា១៤។

[20] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨, មាត្រា១៥។

[21] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨, មាត្រា១៧។

[22] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨, មាត្រា២៩។

[23] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨, មាត្រា១៨។

[24]របាយការណ៍ប្រចាំឆមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន, លេខ ៨៥/១៨ របក (ភ្នំពេញ៖២០១៨), ៥។

**រូបទី១៖ រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌចំការមន**



(ប្រភព៖ ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន២០១៥-២០១៩)

## ១.២. ទិដ្ឋភាពគតិយុត្តនៃការរៀបចំខណ្ឌ និងទិសដៅអភិវឌ្ឍក្នុងខណ្ឌនាពេលអនាគត

### ១.២.១.បច្ចុប្បន្នភាពនៃការរៀបចំខណ្ឌចំការមន

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ របស់រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅចំកណ្ដាលរាជធានីផងនោះ ជាហេតុនាំឱ្យមានប្រជាពលរដ្ឋរស់នៅប្រកបរបរច្រើនប្រភេទ។ជាងនេះទៅទៀត ក្នុងខណ្ឌចំការមន ក៏ឃើញសំបូរទៅដោយសំណង់អគារទំនើបខ្ពស់ៗ និងអគារលំនៅដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ សួនច្បារ មណ្ឌលពាណិជ្ជកម្ម ផ្សារទំនើបសង់អមសងខាងដងវិថីតូចធំ ខ្វាត់ខ្វែងអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលទស្សនា និងទិញទំនិញគ្រប់ប្រភេទ។ ក្រៅពីនេះ នៅជាប់ត្រើយខាងលិចដងទន្លេមេគង្គក្រោមនៅមានមជ្ឈមណ្ឌលពិពណ៌ និងសន្និបាតកោះពេជ្រ និងផ្សារទំនើបអ៊ីអនថ្នាក់អន្តរជាតិដែលសាង់សង់នៅក្នុងភូមិសាស្ត្រសង្កាត់ទន្លេបាសាក់ដែលជាកន្លែងកំសាន្ត លំហែកាយ របស់ប្រជាពលរដ្ឋ ព្រមទាំងមានតាំងលក់នូវទំនិញប្រើប្រាស់ និងអាហារហូបចុកដ៏សំបូរបែបទៀតផង។ មិនតែប៉ុណ្ណោះនៅមានសំណង់អគារតូចធំរបស់ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជន អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលបានបោះទីតាំងនៅក្នុងសង្កាត់ទាំង១២របស់ខណ្ឌចំការមន និង បង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនឆ្លើយតបនូវតម្រូវការជាក់ស្ដែងរបស់មូលដ្ឋាន និងសំណូមពររបស់ប្រជាពលរដ្ឋ។[25]

#### ១.២.១.១.ស្ថានភាពសេដ្ឋកិច្ចក្នុងខណ្ឌចំការមន

##### ១.២.១.១.១.ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

ហេដ្ឋារចនាសម្ព័ន្ធខណ្ឌចំការមនមានមហាវិថីតូច និង ធំប្រវែង ៧៧,៩៤៩ម៉ែត្រ ដែលស្ថាបនាឡើងជាប្រភេទផ្លូវបេតុង ផ្លូវបេទីមីណឺ និងផ្លូវឌីប៊ីអេសធី ដែលបានស្ថាបនាទៅតាមលក្ខណៈភូមិសាស្ត្រជាក់ស្ដែងនៃផ្លូវនីមួយៗ។ បច្ចុប្បន្នខណ្ឌមានផ្លូវអ៊ុតកៅស៊ូបេទីមីណឺប្រវែង ២៥,០៨៦ ម៉ែត្រ ផ្លូវឌីប៊ីអេសធីប្រវែង៤៣,៩៧២ម៉ែត្រ និងផ្លូវបេតុងប្រវែង៨,៨៨៦ម៉ែត្រ សាងសង់ឡើយដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងមួយចំនួនជាថវិកាបដិភាគពីប្រជាពលរដ្ឋមួយចំនួនផងដែរ។[26]

---

[25] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ២០១៨-២០២០, ០៣។

[26] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ២០១៨-២០២០, ០៤។

រាល់ការសាងសង់លើដីសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសលើដីចំណីផ្លូវជាលក្ខណៈអចិន្ត្រៃយ៍ត្រូវបានហាមឃាត់។[27] ការប្រើប្រាស់ដីចំណីផ្លូវ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដូចនេះហាមធ្វើរបងនៅលើចំណីផ្លូវ ហាមសង់លំនៅឋានលើដីចំណីផ្លូវ ហាមទប់ទឹកដែលហូរចេញពីទ្រូវផ្លូវ ហាមជីករាំងព្រួលតាមប្រឡាយលូ ស្ពាន ដែលបណ្ដាលឱ្យរាំងស្ទះចរន្តទឹក។[28]

ទន្ទឹមនឹងការថែទាំ ជួសជុលផ្លូវ រដ្ឋបាលខណ្ឌចំការមនបានដាក់ភ្លើងបំភ្លឺផ្លូវតូចៗ និងច្រកផ្លូវមួយចំនួនព្រមទាំងបានណែនាំគ្រប់សង្កាត់ ចលនាប្រជាពលរដ្ឋក្នុងការចូលរួមក្នុងការដាក់ភ្លើងបំភ្លឺផ្លូវនេះបន្ថែម ដើម្បីរួមចំណែកការពារសន្តិសុខ សុវត្ថិភាពមូលដ្ឋាន និង ងាយស្រួលក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅពេលយប់ឱ្យសមជារាជធានីរបស់ប្រទេស។ ទោះបីរដ្ឋបាលខណ្ឌ និងសង្កាត់ខិតខំអនុវត្តសម្រេចបាននូវសមិទ្ធិផលដ៏ធំធេងយ៉ាងណាក្ដី ក៏នៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ និងត្រូវដោះស្រាយជាបន្តបន្ទាប់ដូចជា៖ ថែទាំជួសជុលផ្លូវដែលមានសំបុកមាន់ជាប្រចាំ និងចាក់បេតុងឆ្អឹងដែក ឬចាក់អ៊ុតកៅស៊ូបេទីមីណើឡើងវិញ ព្រមទាំងពង្រឹងនូវវិធានការត្រួតពិនិត្យបទល្មើសរថយន្តដឹកលើសទម្ងន់ ការតាំងលក់ផលិតផលនៅលើផ្លូវនិងចិញ្ចើមផ្លូវដែលប៉ះពាល់ដល់សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងអ្នកថ្មើរជើងធ្វើដំណើរផងដែរ មិនតែប៉ុណ្ណោះក៏នៅមានច្រកផ្លូវមួយចំនួនត្រូវបានប្រជាពលរដ្ឋសាងសង់លំនៅដ្ឋានថែមទៀតផង បើទោះមានច្បាប់ហាមឃាត់ក៏ដោយ ក៏នៅតែឃើញការអនុវត្តច្បាប់នៅមានការខ្វះចន្លោះ។[29]

### ១.២.១.១.២.សិប្បកម្ម ឧស្សាហកម្មខ្នាតតូច និងមធ្យម

រោងចក្រ និងសិប្បកម្មសំដៅទៅលើអគារ ទីកន្លែង ឬយានយន្ត សម្រាប់ផលិត បំប្លែងវត្ថុធាតុដើម ឬផលិតផលពាក់កណ្ដាលសម្រេចឱ្យទៅជាផលិតផលថ្មី ឬសម្រាប់ធ្វើសកម្មភាពផ្សេងទៀត ដែលមានជាអាទិ៍ ផ្គុំ ដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលម្អ ដើម្បីបម្រើសេចក្ដីត្រូវការទីផ្សារ។[30] ការបង្កើតរោងចក្រសិប្បកម្មត្រូវមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានយោបល់ឯកភាពពីក្រសួង ស្ថាប័ន និងអាជ្ញាពាក់ព័ន្ធ។ការបង្កើតរោងចក្រផ្ដោតសំខាន់ទៅលើ៖ ការរៀបចំទីកន្លែង និងការសាងសង់អគារសម្រាប់

[27] ច្បាប់ស្ដីពីផ្លូវថ្នល់, លេខ នស/រកម/០៥១៤/០០៨, ០៩ ឧសភា ២០១៣,មាត្រា១២។

[28] សេចក្ដីណែនាំស្ដីពីការប្រើប្រាស់ផ្លូវថ្នល់, លេខ០១៥៨ថ, ២០ មករា ២០០៩។

[29] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ២០១៨-២០២០,០៩។

[30] ច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រសិប្បកម្ម, លេខ នស/រកម/០៦០៦/០១៨, ២៣ មិថុនា ២០០៦,មាត្រា២។

ដំណើរការរោងចក្រ ការសាងសង់អគារសម្រាប់បំពាក់ម៉ាស៊ីនដំណើរការរោងចក្រ ការបំពាក់ម៉ាស៊ីនក្នុងអគារ ទីកន្លែង ឬ យានយន្ត សម្រាប់ដំណើរការរោងចក្រ និងវត្ថុធាតុដើមសម្រាប់ដំណើរការរោងចក្រ។[31]

ក្នុងចំណោមសង្កាត់ទាំង១២ របស់ខណ្ឌចំការមនដែលសំបូរសិប្បកម្មរួមមាន: សង្កាត់ទន្លេបាសាក់ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិក សង្កាត់បឹងត្របែក និងសង្កាត់ផ្សារដើមថ្កូវ។ ដោយក្នុងសង្កាត់ទាំងនោះបាននឹងកំពុងផលិតនូវឧបករណ៍ប្រើប្រាស់ អាហារហូបចុក សិប្បកម្មផលិតគ្រឿងសង្ហារឹមដែលធ្វើអំពីឈើ វ័ល្លិ៍ ផ្តៅ សិប្បកម្មអំពីដែក កញ្ចក់ អាលុយមីញ៉ូម ទឹកបរិសុទ្ធ និងសិប្បកម្មតម្លើងនូវម៉ាស៊ីនលាយបេតុង ម៉ាស៊ីនច្រៀកឈើ អារឈើជាដើម...។ល។ រីឯរោងចក្រធុនតូច និងមធ្យម មានរោងចក្រកាត់ដេរ សម្លៀកបំពាក់ និងរោងចក្រផលិតទឹកកកជាដើមនោះ បានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច កាន់តែប្រសើរឡើង មិនតែប៉ុណ្ណោះបានផ្តល់នូវឱកាសការងារជូនដល់ប្រជាពលរដ្ឋតាមបណ្តាខេត្តនានាៗ ក្នុងព្រះរាជាណាចក្រកម្ពុជា
មួយចំនួនដែលមកធ្វើការនៅរាជធានីភ្នំពេញ ហើយក៏ជាឱកាសក្នុងការកាត់បន្ថយការចំណាកស្រុកទៅក្រៅប្រទេសផងដែរ។

ទន្ទឹមនឹងភាពរីកចម្រើន ក៏នៅមានសិប្បកម្មមួយចំនួនផលិតចំណីអាហារនៅមានប្រើសារធាតុគីមីដែលខុសលក្ខណៈបច្ចេកទេសខ្វះអនាម័យ គ្មានសុវត្ថិភាព និងពុំទាន់ធានាបាននូវគុណភាពសោភ័ណភាពនៅឡើយ ហើយទីតាំងមួយចំនួនដំណើរការដោយពុំទាន់មានច្បាប់អនុញ្ញាតដែលទាមទារឱ្យរដ្ឋបាលបង្កើនការគ្រប់គ្រង និង ត្រួតពិនិត្យជាប្រចាំដោយសហការជាមួយអង្គភាពជំនាញ។[32]

### ១.២.១.២.ស្ថានភាពសង្គមកិច្ចក្នុងខណ្ឌចំការមន

#### ១.២.១.២.១.ការងារអប់រំ

ក្នុងខណ្ឌចំការមននាពេលបច្ចុប្បន្ន គឺមានគ្រឹះស្ថានអប់រំសាធារណៈ និងឯកជន ចាប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ដែលធានាឱ្យកូនចៅប្រជាពលរដ្ឋមានលទ្ធភាពបានចូលរៀនគ្រប់ៗគ្នា។ ទោះបីជាមានគ្រឹះស្ថានអប់រំច្រើនហើយក្តី ក៏នៅមានកុមារមួយចំនួនពុំ បានរៀនចប់ត្រឹមថ្នាក់ទី៩ ដូចការកំណត់រយៈពេលសិក្សាបានយ៉ាងទាប៩ឆ្នាំ ស្របតាមកម្មវិធី

---

[31] ច្បាប់ស្តីពីការវិសោធនកម្មច្បាប់ការគ្រប់គ្រងរោងចក្រសិប្បកម្ម, លេខ នស/រកម/១០១៩/០២៥, ២៣ តុលា ២០១៩, មាត្រា៥។

[32] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ២០១៨-២០២០, ០៥។

អប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ បញ្ហានេះកើតឡើង ដោយសារនៅមានឪពុកម្តាយមួយចំនួនពុំទាន់យល់អំពីសារសំខាន់នៃការសិក្សា និងម៉្យាងទៀតជីវភាពគ្រួសារមានការខ្វះខាតផងនោះ ជំរុញឱ្យឪពុកម្តាយមួយចំនួនឱ្យកូនឈប់រៀន ដើម្បីជួយរកចំណូលគ្រួសារ។ បើទោះជាមានការជួបប្រទះនូវបញ្ហាប្រឈមដូច្នេះក៏ដោយ ក៏រដ្ឋបាលខណ្ឌនៅតែបន្តការជំរុញកុមារឱ្យបានចូលរៀនគ្រប់ៗគ្នាតាមរយៈការខិតខំអប់រំដល់ក្រុមគ្រួសាររបស់កុមារទាំងនោះ ហើយបានធ្វើការសហការជាមួយការិយាល័យអប់រំខណ្ឌ គណៈកម្មាធិការកិច្ចការនារី និងកុមារ ក្នុងការស្រង់ស្ថិតិសិស្សបោះបង់ការសិក្សា ដោយធ្វើការពន្យល់ណែនាំ ជួយឧបត្ថម្ភសម្ភារៈសិក្សានិងសម្ភារៈប្រើប្រាស់មួយចំនួនដល់ពួកគាត់ ជាការលើកទឹកចិត្តឱ្យពួកគាត់បានចូលរៀនជាធម្មតាវិញ។

តាមទិន្នន័យដែលមាន ខណ្ឌចំការមនមានចំនួនសាលាមត្តេយ្យក្នុងឆ្នាំ២០១៣ នៅក្នុងខណ្ឌសរុប ៣៩សាលា មានសិស្សសរុប ៨,៦៧៤នាក់ និងគ្រូបង្រៀន ៤៤៤នាក់សាលាបឋមសិក្សាសរុប ២៨សាលា មានសិស្សសរុប ១៣,៣៦៦នាក់ និងគ្រូបង្រៀន ៧២១នាក់ អនុវិទ្យាល័យសរុប១៧សាលា មានសិស្សសរុប ៩,៤០៤នាក់ និងគ្រូបង្រៀន ៧៨២នាក់ វិទ្យាល័យសរុប២៦សាលាមានសិស្សសរុប ១៥,៨៤១នាក់ និងគ្រូបង្រៀន ១,០៤៨នាក់។[33]

### ១.២.១.២.២.ការថែរសុខាភិបាល

សេវាថែទាំសុខភាពក្នុងខណ្ឌចំការមន គឺមានច្រើនទីតាំងទាំងរដ្ឋ និងឯកជនបាននឹងកំពុងធ្វើសកម្មភាព  នៅក្នុងមូលដ្ឋានខណ្ឌ ដើម្បីជួយពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ដោយមានវេជ្ជបណ្ឌិតជំនាញៗ និងមានសម្ភារៈបច្ចេកវិទ្យាទំនើបមិនចាញ់ប្រទេសជិតខាងឡើយ។ ក្រៅពីការធ្វើសកម្មភាពនៅនឹងកន្លែងហើយនោះ ក្រុមគ្រូពេទ្យថែមទាំងបានចុះយុទ្ធនាការចាក់ថ្នាំបង្ការនានាជូនដល់ស្ត្រី និងកុមារតាមមូលដ្ឋានហើយមន្ទីរសុខាភិបាលរាជធានីភ្នំពេញបានសហការជាមួយសាលារៀនដែលមានក្នុងសង្កាត់ ក្នុងការផ្តល់នូវថ្នាំទំលាក់ព្រូនដល់សិស្សានុសិស្សដែលកំពុងរៀននៅបឋមសិក្សាព្រមទាំងចុះអប់រំប្រជាពលរដ្ឋឱ្យចេះថែទាំសុខភាព និងរក្សាអនាម័យភូមិដ្ឋាន ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។

ក្នុងខណ្ឌចំការមននេះផងដែរ តាមរបាយការណ៍គឺមានចំនួនមណ្ឌលសុខភាព ០២កន្លែង មន្ទីរពេទ្យបង្អែក ០១កន្លែង និងមន្ទីរពេទ្យឯកជន ១៨កន្លែង។[34]

[33] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ០៩។

[34] ខណ្ឌចំការមន,*ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ១៧។

### ១.២.១.៣.ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

រដ្ឋបាលខណ្ឌខិតខំយកចិត្តទុកដាក់បង្កើតគ្រប់វិធានការ ដើម្បីថែរក្សាការពារផលប៉ះពាល់ដល់ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងធានាបានការប្រើប្រាស់ប្រកបដោយសន្តិភាព និរន្តភាព[35] ស្របតាមបញ្ញត្តិច្បាប់ភូមិបាល និងអនុក្រឹត្យលេខ៨៦ ស្តីពីការអនុញ្ញាតសាងសង់លំនៅដ្ឋាន និងសារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ខុសច្បាប់ តាមរាជធានី ទីក្រុង ទីប្រជុំជន ។

#### ១.២.១.៣.១.ការងារគ្រប់គ្រងដីធ្លី និងសំណង់

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅដ្ឋាន[36] ហើយរាល់រូបវ័ន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយច្បាប់ដែលពាក់ព័ន្ធ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញឱ្យមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់[37]។

ចំពោះខណ្ឌចំការមនវិញ ប្រជាពលរដ្ឋដែលរស់នៅក្នុងដែនសមត្ថកិច្ចខណ្ឌ បានទទួលនូវប្លង់កម្មសិទ្ធិស្របច្បាប់បានចំនួន១៦,៥៥៨គ្រួសារធៀបទៅនឹងគ្រួសារកំពុងរស់នៅមានចំនួន២០,០១១ គ្រួសារ គឺស្មើ៨២.៧៤% ចំណែកគ្រួសារដែលមិនទាន់បានទទួល អង្គភាពជំនាញកំពុងបន្តរៀបចំជាបណ្តើរៗ ដើម្បីឱ្យសំរេចបានតាមទិសដៅនាពេលអនាគតរបស់ខណ្ឌដែលបានកំណត់ ។[38]

#### ១.២.១.៣.២.ការងារបរិស្ថាន

ការបំពុលបរិស្ថាននៅកម្ពុជាកំពុងរីករាលដាលគួរឱ្យព្រួយបារម្ភ ដោយសារកំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ក្នុងនោះវិស័យឧស្សាហកម្ម ដូចជា ឧស្សាហកម្មកាត់ដេរ, ឡឥដ្ឋ, រោងម៉ាស៊ីនកិនស្រូវ និង ឧស្សាហកម្មកែច្នៃកៅស៊ូដែលជាវិស័យដ៏សំខាន់មួយចំពោះសេដ្ឋកិច្ចកម្ពុជាកំពុងតែបង្កឱ្យមានការបំពុលបរិស្ថាន។[39]

ប្រព័ន្ធលូក៏ជាកត្តាសំខាន់ដែលពាក់ព័ន្ធនឹងបរិស្ថាន បន្ទាប់ពីសកម្មភាពឧស្សាហកម្មព្រោះតំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ ប

---

[35] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ២៥។

[36] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ មាត្រា២៥-១ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឆ្នាំ១៩៦៦ មាត្រា១១-១

[37] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា១។

[38] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ២០១៨-២០២០, ១៥។

[39] ចូលមើលលើកចុងក្រោយថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ https://opendevelopmentcambodia.net/km/topics/pollution-and-waste/

ណ្តាញលូមេរង បណ្តាញលូខ្វែង និង បណ្តាញលូខ្វែងរង) គឺជាប្រព័ន្ធលូដែលប្រមូល និង បង្ហូរទឹកកខ្វក់។[40] ដូច្នេះហើយទើប ខណ្ឌចំការមនបានរៀបចំនូវបណ្តាញលូបង្ហូរទឹកដែលមានសភាពចាស់ទ្រុឌទ្រោមឡើងវិញ ដើម្បីធានានូវចរន្តទឹកហូរបានកាន់តែប្រសើរ ក្នុងគោលដៅបញ្ចៀសមិនឱ្យមានទឹកដក់នៅលើទ្រូងផ្លូវយូរនៅពេលមានភ្លៀវធ្លាក់ដូចពេលមុនៗ។ បញ្ហាលិចផ្លូវនៅពេលភ្លៀវធ្លាក់ខ្លាំងម្តងៗ ពិសេសនៅតាមមាត់ប្រឡាយបឹងត្របែក គឺដោយសារភូមិសាស្ត្រខណ្ឌចំការមនជាផ្នែកមួយនៃរាជធានីដែលទទួលរងនូវចរន្តទឹកហូរធ្លាក់ពីខណ្ឌ៧មករា និងមួយផ្នែកទៀតមកពីខណ្ឌដូនពេញ ដោយចរន្តទឹកហូរចូលអាងស្តុកមិនទាន់ ហើយអាងនេះថែមទាំងគោករាក់ ព្រោះពុំសូវបានស្តារប្រមូលផ្តុំទាំងកម្លាំងនៃការបូមរបស់ស្ថានីយមិនអាចធានានូវបរិមាណទឹកហូរចូលបាន។ ដោយឡែកចំពោះការងារគ្រប់គ្រង និងប្រមូលសំរាម រដ្ឋបាលខណ្ឌបានសហការល្អជាមួយក្រុមហ៊ុន ស៊ីន ទ្រី ដោយបែងចែកកម្មវិធី និងពេលវេលាច្បាស់លាស់ក្នុងការប្រមូលដោយ មិនមានសំរាមកកស្ទះយូរថ្ងៃឡើយ។ លើសពីនេះទៅទៀតរដ្ឋបាលខណ្ឌក៏បានអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការទុកដាក់ និងវេចខ្ចប់សំរាមបានត្រឹមត្រូវផងដែរ។ ប៉ុន្តែទោះជាណាក្តី ក៏យើងនៅសង្កេតឃើញមានប្រជាពលរដ្ឋមួយចំនួនតូចពុំបានយកចិត្តទុកដាក់ក្នុងការវេចខ្ចប់សំរាមបានល្អនូវ
ឡើយ។[41]

### ១.២.២.ទិសដៅនិងយុទ្ធសាស្ត្រអភិវឌ្ឍក្នុងខណ្ឌចំការមននាពេលអនាគត

គោលបំណងក្នុងការអភិវឌ្ឍរបស់ខណ្ឌចំការមននាពេលអនាគត គឺធ្វើការលើកស្ទួយនូវជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យមានការរីកចម្រើនតាមរយៈការរៀបចំផែនការអភិវឌ្ឍ ទៅតាមវិស័យនីមួយៗប្រកបដោយ សមភាព តម្លាភាព និងគណនេយ្យភាពដូចជា៖

#### ១.២.២.១.ផ្នែកសេដ្ឋកិច្ច

ដើម្បីសម្រេចគោលដៅក្នុងការអនុវត្តគម្រោងផែនការរដ្ឋបាលខណ្ឌ ក្រុមប្រឹក្សាបានរៀបចំសកម្មភាពតាមជំហាននីមួយៗ ដូចតទៅគឺ៖ គម្រោងការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឆ្នាំ ២០១៩ ដោយខណ្ឌនឹងត្រូវធ្វើការជួសជុលដោយ ចាប់អ៊ុតកៅស៊ូAC និងចាក់បេតុងឆ្អឹងដែកហើយ ១០០ភាគរយ ក្នុងគោលបំណងរៀបចំហេដ្ឋារចនាសម័ន្ធផ្លូវថ្នល់ឱ្យលែងមានជង្ហុក និងទឹកដក់នៅរដូវវស្សា ព្រមទាំងធានាឱ្យខណ្ឌមានសោភ័ណភាពបន្ថែមដោយការដាក់ភ្លើងអមសងខាងផ្លូវ ដើម្បីឱ្យប្រជាពលរដ្ឋមានសុខសុវត្ថិភាពនាពេលធ្វើដំណើរនៅពេលយប់។ រីឯយុទ្ធសាស្ត្រក្នុង

[40] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥អនក្រ/បក, ២៥ ធ្នូ ២០១៧, មាត្រា៤។
[41] ចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ២៦។

ការអភិវឌ្ឍនៅក្នុងវិស័យនេះ គឺរដ្ឋបាលខណ្ឌចំការមនបានធ្វើការកែប្រែផ្លូវឌីប៊ីអេសធី ឬផ្លូវម៉ាកាដាមឱ្យទៅជាផ្លូវអ៊ុតកៅស៊ូបេទីមីណឺ ពីផ្លូវចាក់បេតុងឆ្អឹងឬស្សីទៅជាផ្លូវបេតុងឆ្អឹងដែក បណ្ដាញលូដែលមានមុខកាត់តូច និងពុកផុយត្រូវប្ដូរចេញដោយដាក់លូដែលមានគុណភាពរឹងមាំចាប់ពីទំហំមុខកាត់ ០,៥០ម៉ែត្រ ឡើងទៅ។ រីឯតាមដងវិថីនិងច្រកផ្លូវរដ្ឋបាលខណ្ឌគឺមានរៀបចំដាក់នូវអំពូលភ្លើងអគ្គិសនីបំភ្លឺនៅពេលយប់ ព្រមទាំងបង្កើតនូវក្រុមការងារតាមដានត្រួតពិនិត្យជាប្រចាំ ជៀសវាងរងការបំផ្លាញពីជនខិលខូចមួយចំនួន។

### ១.២.២.២.ផ្នែកសង្គមកិច្ច

គោលដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគត គឺរដ្ឋបាលខណ្ឌនឹងធានាឱ្យបាននូវសុខភាពប្រជាពលរដ្ឋដោយគ្មានការកើតឡើងនូវជំងឺឆ្លងនានាគ្រប់ប្រភេទ និង ទប់ស្កាត់ការកើតមានឱសថក្លែងក្លាយ និងគ្មានគុណភាពដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពក៏ដូចជាអាយុជីវិតរបស់ប្រជាពលរដ្ឋ។ទន្ទឹមនឹងនោះរដ្ឋបាលខណ្ឌក៏មានគោលដៅក្នុងការជំរុញឱ្យកុមារគ្រប់អាយុបានចូលរៀនគ្រប់ៗគ្នា ក្នុងគោលបំណងលើកកម្ពស់វិស័យអប់រំនៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង។ រីឯយុទ្ធសាស្ត្រអភិវឌ្ឍវិញ គឺរដ្ឋបាលខណ្ឌត្រូវបន្តអប់រំផ្សព្វផ្សាយ ឱ្យប្រជាពលរដ្ឋកាន់តែយល់ដឹងបន្ថែមអំពី ការចូលរួមការរក្សានូវទំនៀមទំលាប់ ប្រពៃណី វប្បធម៌ ជំនឿ សាសនា និងពង្រឹងបន្ថែមទៅលើវិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងយេនឌ័រ។

### ១.២.២.៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន

គោលដៅចម្បងក្នុងឆ្នាំ ២០១៩ គឺផ្ដល់ប្លង់កម្មសិទ្ធិដី និងផ្ទះ ជូនប្រជាពលរដ្ឋចប់១០០% ទប់ស្កាត់ឱ្យបាននូវសកម្មភាពចាក់ដីលុបបឹងធម្មជាតិបឹងត្របែក ដោយរដ្ឋបាលខណ្ឌបានយកចិត្តទុកដាក់ទប់ស្កាត់យ៉ាងសកម្មរាល់បទល្មើសនេះ ព្រមទាំងមានផែនការស្តារភក់ឱ្យបានជ្រៅបន្ថែមទៀត ដើម្បីបញ្ចៀសបានក្នុងការជនលិចរាជធានីនៅរដូវវស្សា។ លើសពីនេះទៅទៀត រដ្ឋបាលខណ្ឌក៏មាននូវផែនការរៀបចំជា វគ្គផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋចូលរួមប្រុងប្រយ័ត្ន និងចូលរួមក្នុងវិធានការការពារ និងថែរក្សាបរិស្ថានដោយមានការដាំដើមឈើនៅសង្កាត់នីមួយៗ។[42]

### ១.២.២.៤.ផ្នែករដ្ឋបាល និងសន្តិសុខ

ចំពោះគោលដៅអភិវឌ្ឍលើផ្នែករដ្ឋបាល និងសន្តិសុខទៅថ្ងៃអនាគតរបស់ខណ្ឌចំការមន ដែលនឹងសម្រេចបានក្នុងឆ្នាំ ២០១៩ខាងមុខ គឺពង្រឹងការងារផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យបានលឿន និងឆាប់រហ័ស រួមទាំង ទប់ស្កាត់រាល់បទល្មើស លួច ឆក់ ប្លន់កុំឲ្យកើតមានក្នុងមូលដ្ឋាន។ ក្នុងនោះដែរ រដ្ឋបាលខណ្ឌក៏មានយុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ

[42] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ៣០។

សណ្តាប់ធ្នាប់សាធារណៈដោយធានាក្នុងការផ្តល់សេវាសាធារណៈតាមរយៈការិយាល័យច្រកចេញចូលតែមួយជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធិភាព តម្លាភាព សមភាព និងគណនេយ្យភាពបានទាន់ពេលវេលា។ ចំពោះផ្នែកសន្តិសុខសណ្តាប់ធ្នាប់វិញ គឺរដ្ឋបាលខណ្ឌក៏បានបន្តផ្សព្វផ្សាយច្បាប់ គោលនយោបាយជូនដល់ប្រជាពលរដ្ឋដើម្បីចូលរួមទប់ស្កាត់អំពើលួច ឆក់ ប្លន់ ការជួញដូរ និងសេពគ្រឿងញៀន ព្រមទាំងរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋានឱ្យបានកាន់តែប្រសើរថែមទៀត។[43]

## ជំពូកទី ២

## សោភ័ណភាពក្នុងខណ្ឌចំការមន

សោភ័ណភាព បរិស្ថាន និងអនាម័យ ជាកត្តាដែលគួរទទួលបាននូវការរៀបចំឱ្យមានលក្ខណៈល្អប្រសើរ ដើម្បីលើកកម្ពស់ទីក្រុងស្អាត ទាក់ទាញភ្ញៀវទេសចរណ៍ ផ្តល់ជាសុកភាព និងសុខុមាលភាពល្អចំពោះប្រជាជន។ នៅលើពិភពលោកទាំងក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ គឺសុទ្ធតែយកចិត្តទុកដាក់ទៅលើការលើកកម្ពស់សោភ័ណភាព និងចង់បានបំផុតនូវអនាម័យ ព្រមទាំងបរិស្ថានល្អ។ ចំពោះខណ្ឌចំការមនដែលជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង ១២នៃរាជធានីភ្នំពេញវិញ ក៏បានផ្តោតសំខាន់ទៅលើបញ្ហាសោភ័ណភាព បរិស្ថាន និងអនាម័យល្អប្រសើរផងដែរតាមរយៈការអនុវត្ត និងដាក់ចេញនូវផែនការណ៍ផ្សេងៗកែលម្អសោភ័ណភាព បរិស្ថាន និងអនាម័យក្នុងខណ្ឌ។

[43] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ៣០។

ជាក់ស្តែងប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ ហើយទន្ទឹមនឹងការអភិវឌ្ឍ គឺជៀសមិនផុតពីបញ្ហាដែលបង្កឱ្យមានការបំពុលឡើយ។ ការបំពុលដែលនឹងកើតឡើងជាកត្តាជំរុញឱ្យមានការស្វែងរកនូវហេតុបង្ក ក៏ដូចជាដំណោះស្រាយនានាដើម្បីធ្វើយ៉ាងណារក្សាបាននូវសោភ័ណភាពល្អបរិស្ថានស្អាត។

## ២.១. ហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន និងយន្តការក្នុងការរៀបចំសោភ័ណភាពក្នុងខណ្ឌចំការមន

### ២.១.១. ហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន

បញ្ហានៃការបំពុលបរិស្ថាន គឺជាការព្រួយបារម្ភចម្បងមួយដែលប្រជាជន និងរដ្ឋាភិបាលនានាកំពុងតែប្រឈមមុខ។ ទន្ទឹមនឹងការអភិវឌ្ឍទៅមុខ បញ្ហាផ្សេងៗជាច្រើនប្រាកដជាកើតមានឡើងជាមួយគ្នាផងដែរ ហើយបញ្ហាបរិស្ថាន គឺទទួលរងឥទ្ធិពលអវិជ្ជមានខ្លាំងជាងគេក្នុងចំណោមបញ្ហាទាំងអស់នោះ។ ជាក់ស្តែងនៅប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ក៏កំពុងតែជួបប្រទះនូវបញ្ហានៃការបំពុលបរិស្ថានដែរ ដោយសារកំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជៀសមិនផុតឡើយពីការបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់ៗ រួមទាំងការបំពុល ទឹក ខ្យល់ សំណល់រឹងរាវ និងសម្លេង។[44] ការស្វែងរកដំណោះស្រាយទាក់ទងនឹងការបំពុលគឺជាការសំខាន់ណាស់ ដោយសារមនុស្សជាផ្នែកមួយនៃបរិស្ថាននិងថែមទាំងមិនអាចផ្តាច់ខ្លួនចេញបានក៏ព្រោះបរិស្ថានសំដៅដល់អ្វីៗដែលនៅជុំវិញខ្លួនយើង។ ទោះយ៉ាងណាក្តីមុននឹងអាចស្វែងរកនូវដំណោះស្រាយយើងគួរដឹងអំពីមូលហេតុនៃការបំពុលសិន។

#### ២.១.១.១. ហេតុបង្កនាំឱ្យមានការបំពុលទឹក ដី និងខ្យល់

ទឹក ដី ខ្យល់ គឺជាធនធានធម្មជាតិដ៏សំខាន់ដែលទ្រទ្រង់ជីវិតរស់នៅរបស់មនុស្ស។ ប៉ុន្តែនាពេលបច្ចុប្បន្នធនធានទាំង ៣ នេះកំពុងប្រឈមមុខនឹង ផលប៉ះពាល់អវិជ្ជមានគួរឱ្យព្រួយបារម្ភពីសំណាក់កត្តាផ្សេងៗ ហើយការទុកដាក់សំរាមមិនបានត្រឹមត្រូវ គឺជាកត្តាចម្បងមួយដែលបង្កឱ្យ ទឹក ដី និងខ្យល់ទទួលរងការបំពុល។

##### ២.១.១.១.១. ហេតុបង្កនាំឱ្យមានការបំពុលទឹក

នៅគ្រប់ផ្នែកនៃបរិស្ថាន និងចំពោះរាល់ភាវៈមានជីវិត គឺសុទ្ធតែត្រូវការទឹកជាចាំបាច់។ ទឹកក៏បានដើរតួនាទីជាចំណែកមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសមួយឱ្យជឿនលឿនផងដែរ

[44] ចូលមើលលើកចុងក្រោយ ១៧ ឧសភា ២០១៨, https://opendevelopmentcambodia.net/km/topics/pollution-and-waste/#ref-74643-2។

ដូចជាចំពោះលើវិស័យឧស្សាហកម្ម កសិកម្ម ទេសចរណ៍ គមនាគមន៍ និងតំបន់ទីក្រុង។ ប៉ុន្តែការលេចចេញនូវឥទ្ធិពលអវិជ្ជមានទៅលើគុណភាពបរិស្ថានទឹក ដោយសារសំណល់ឧស្សាហកម្ម សំណល់គីមីរាប់ម៉ឺនប្រភេទ រួមទាំងកាកសំណល់ដែលមានផ្ទុកជាតិពុលផ្សេងៗជាច្រើនទៀត ឬការចោលសំរាម លាមក ទៅតាមប្រព័ន្ធលូបង្ហូរទឹក គឺបណ្តាលឱ្យបរិស្ថានទឹកត្រូវបានបំពុល ហើយនឹងប្រែជាផ្តល់នូវផលវិបាកដល់ជីវិតមនុស្ស សត្វ ទៅវិញ។

ការបំពុលបរិស្ថានទឹក គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យទឹកប្រែប្រួលខុសពីលក្ខណៈដើម។ សោភ័ណភាពបរិស្ថានអាចទទួលរងការជះឥទ្ធិពលអាក្រក់កម្រិតណាពីសំណាក់ការបំពុលទឹក គឺអាស្រ័យទៅតាមស្ថានភាពនៃការបំពុលដែលភាគច្រើនមាននៅតាមទីកន្លែងសំខាន់ៗមួយចំនួន ដូចជា រមណីយដ្ឋាន ទីក្រុង ទីប្រជុំជន ទីកន្លែងកម្សាន្ត និងទីសាធារណៈជាដើម។[45]

ការគ្រប់គ្រងកាកសំណល់ជីគីមី ក៏ដូចជាថ្នាំសំលាប់កត្តាចង្រៃបន្សល់ពីវិស័យកសិកម្ម ការបង្ហូរកាកសំណល់ចេញពីរោងចក្រ ឬកសិដ្ឋានចិញ្ចឹមសត្វផ្សេងៗមិនបានត្រឹមត្រូវតាមបច្ចេកទេសបណ្តាលឱ្យទឹកត្រូវបានបំពុលតាមរយៈកាកសំណល់ហូរធ្លាក់ចូលប្រឡាយទឹក។[46] ម្យ៉ាងវិញទៀតមិនមែនមានតែសកម្មភាពទាក់ទងនឹងការគ្រប់គ្រងប្រើប្រាស់ជីគីមីមិនបានត្រឹមត្រូវប៉ុណ្ណោះទេ ដែលបង្កឱ្យមានការបំពុលទឹក ប៉ុន្តែសកម្មភាពរស់នៅប្រចាំថ្ងៃក៏រួមចំណែកផងដែរ។ ជាក់ស្តែងចំពោះការចោលកាកសំណល់ផ្ទះបាយទាំងសំណល់សរីរាង្គដែលសំដៅលើសំណល់បន្លែ ផ្លែឈើ ត្រី សាច់ ឬវត្ថុធាតុអាចបំបែក ឬរលួយបាន និងសំណល់អសរីរាង្គដែលសំដៅលើថង់ផ្លាស្ទិក សម្បកកំប៉ុង សម្បកដបឬលោហធាតុផ្សេងៗដែលមិនអាចរលាយបាន គឺសុទ្ធតែជាសកម្មភាពបង្កការបំពុល។ នៅពេលសំរាម ឬ កាកសំណល់ទាំងនោះស្អុយរលួយនឹងនាំឱ្យមានការបំពុលប្រព័ន្ធទឹកប្រើប្រាស់តាមរយៈទឹកភ្លៀង។ ហើយការហូរចូលទៅក្នុងទឹកស្ទឹង ទន្លេ បឹង ជ្រាបទៅក្រោមដីបង្កជាហេតុអាចបំពុលដល់ទឹកនៅក្រោមដី។[47] នៅតាមទីក្រុង ឬទីសាធារណៈ ការបោះសំរាម ឬកាកសំណល់រឹងរាវផ្សេងៗពាសវាលពាសកាលហើយពេលខ្លះថែមទាំងបោះចោលទៅក្នុងទឹកទៀតនោះបានបណ្តាលឱ្យមានផលប៉ះពាល់ខ្លាំងណាស់លើគុណភាពនៃទឹក។[48]

[45] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

[46] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

[47] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

[48] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

រោងចក្រ និងសិប្បកម្មមួយចំនួនដែលមានទីតាំងជាប់នឹងមាត់ទន្លេបានធ្វើការបង្ហូរកាកសំណល់មិនទាន់ទទួលបានការច្រោះសម្អាត មុននឹងបញ្ចេញដោយផ្ទាល់ចូលទៅក្នុងប្រព័ន្ធទឹកតែម្តងនោះ ក៏ជាហេតុបង្កផលប៉ះពាល់យ៉ាងខ្លាំងគួរឱ្យបារម្ភចំពោះបរិស្ថានទឹក ។[49]

អាកាសធាតុ ក៏អាចជាកត្តាបំពុលបរិស្ថានទឹកបានតាមរយៈទឹកភ្លៀង។ សារធាតុនីត្រូសែនដែលមានផ្ទុកនៅក្នុងទឹកភ្លៀងបំពុលទឹកនៅពេលទឹកភ្លៀងធ្លាក់ចូលក្នុងទឹកស្ទឹង បឹង ស្រះ ឬទន្លេ ហើយនឹងបង្កជាគ្រោះថ្នាក់ផ្សេងៗចំពោះសុខភាពមនុស្ស សត្វ តាមរយៈការប្រើប្រាស់ ឬបរិភោគ។ សារធាតុនេះក៏មានឥទ្ធិពលបំផ្លាញរុក្ខជាតិ ព្រមទាំងជីវិតជីវចម្រុះដែលរស់នៅក្នុងទឹកផងដែរ។[50]

សកម្មភាពនៃការបំពុលបរិស្ថានទឹកជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើបរិស្ថាន ហើយក៏ប៉ះពាល់ដោយផ្ទាល់ និងប្រយោលដល់ មនុស្ស សត្វ រុក្ខជាតិ ព្រមទាំងសោភ័ណភាពនៃទីក្រុង ឬតំបន់សាធារណៈផ្សេងៗផងដែរ។ ការប្រើប្រាស់ទឹកស្អាត និងប្រកបដោយនិរន្តរភាពនៅតែជាបញ្ហាប្រឈមមួយ ជាពិសេសគ្រួសារនៅតាមជនបទ។[51] តាមរយៈការប្រើប្រាស់ និងបរិភោគទឹកមិនស្អាតអាចបណ្តាលឱ្យកើតមានបញ្ហាសុខភាពជាច្រើនដូចជា ជំងឺគ្រុនពោះវៀន ជំងឺគ្រុនចាញ់ អាសន្នរោគ រលាកថ្លើម ឃ្លង់ គ្រុនឈឿង រាគ និងជំងឺផ្សេងៗច្រើនទៀត ដោយសារទឹកពោរពេញទៅដោយមេរោគ។ លើសពីនេះទៅទៀត ការបំពុលទឹកក៏ប៉ះពាល់ទៅដល់វិស័យកសិកម្មផងដែរ នៅពេលមានការយកទឹកដែលពោរពេញទៅដោយសារធាតុគីមីបង្កដោយកាកសំណល់រឹង ប្លាស្ទិក កប់នៅក្នុងដី និងត្រាំក្នុងទឹកទៅស្រោចស្រពដំណាំ។ ចំណែកផលប៉ះពាល់បរិស្ថានវិញ គឺការបំពុលទឹកបានបង្កឱ្យមានការប្រែប្រួលអាកាសធាតុ និងឡើងកម្តៅ។ នេះបើយោងតាមការឱ្យដឹងពីសំណាក់អ្នកឯកទេសទឹកស្អាត និងអនាម័យនៃអង្គការផ្លែនអន្តរជាតិ-កម្ពុជា (Plan International) លោក ហាង់ ហ៊ីប៊ុណ្ណា។[52] ចំពោះផលប៉ះពាល់នៃការបំពុលទឹកដល់សោភ័ណភាពនោះ គឺបរិស្ថានទឹកមិនល្អអាចនាំឱ្យមានការថយចុះនូវមោទនភាពរបស់បុគ្គល និងសហគមន៍ ហើយនឹងអាចមានផលរំខានរវាងមនុស្សនិងមនុស្សគ្មានការលើកទឹកចិត្តវិនិយោគធ្វើឱ្យមានផលប៉ះពាល់ទៅដល់សង្គម និងស្ថានភាពជាច្រើនប្រភេទទៀត។[53]

---

[49] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៧១។

[50] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

[51] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, https://opendevelopmentcambodia.net/km/topics/water-pollution/។

[52] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, https://www.rfa.org/khmer/program/health/Health-effects-people-use-dirty-water-12152016033054.html។

[53] ចូលមើលលើកចុងក្រោយ ១៨ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

### ២.១.១.១.២. ហេតុបង្កនាំឱ្យមានការបំពុលដី

ការបំពុលដីជាបញ្ហាប្រឈមមួយដែលគួរឱ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ន បើទោះបីជាវាមិនសូវជះឥទ្ធិពលដល់អ្នករស់នៅកណ្ដាលទីក្រុងប៉ុន្មានក៏ដោយ។ ប៉ុន្តែការបំពុលដីនៅតែជាបញ្ហាប្រឈមមួយចំពោះអ្នករស់នៅប្រកបរបរកសិកម្មនៅតាមបណ្ដាជាយៗក្រុង។

កំណើនប្រជាជនកាន់តែកើន គំនរសំរាមក៏មានចំនួនច្រើនឡើងដែរ ហើយត្រូវការប្រើប្រាស់ដីរឹតតែច្រើនដើម្បីគរសំរាម។ សំរាម គឺជាកត្តាចំបងមួយដែលបណ្ដាលឱ្យដីទទួលរងការបំពុល។ ការគរសំរាមនៅទីកន្លែងណាមួយរយៈពេលយូរដូចជា ទីលានចាក់សំរាម ជាដើម គឺនឹងបណ្ដាលឱ្យដីនៅត្រង់តំបន់នោះខូចគុណភាព ឬបាត់បង់នូវជីវជាតិ។[54] ការទុកដាក់សំរាមមិនបានត្រឹមត្រូវ ឬចោលសំរាមរាយប៉ាយទៅលើដី គឺជាហេតុបណ្ដាលឱ្យមានការប៉ះពាល់ដល់ដី ជាពិសេសចំពោះប្រភេទនៃសំណល់សំរាមដែលមិនអាចកែច្នៃឡើងវិញបាន ឬកាកសំណល់ចេញពីគ្រួសារនីមួយៗ។ ភាគច្រើននៅពេលកាកសំណល់នេះកើនឡើងច្រើនវានឹងត្រូវកប់លាយឡំនៅក្នុងរណ្ដៅដែលគេហៅថា ជាកន្លែងចោលសំរាម។ សំរាមមួយចំនួនដែលកប់ក្នុងដីត្រូវប្រើរយៈពេលយូរណាស់ទើបអាចរលាយអស់ទាំងស្រុង ខណៈដែលកាកសំណល់ ឬសំរាមមួយចំនួនទៀតមានផ្ទុកសារធាតុពុល ជាហេតុបណ្ដាលឱ្យដីទទួលរងការខូចខាតមិនអាចយកមកប្រើប្រាស់បាន បើទោះជាក្នុងវិស័យកសិកម្ម ឬសំណង់ក៏ដោយ។

កាកសំណល់ជាច្រើនដែលបញ្ចេញពីឧស្សាហកម្មធុនធ្ងន់បានបង្កផលប៉ះពាល់ដល់គុណភាពដីគួរឱ្យព្រួយបារម្ភ។ ភាគច្រើន គឺពាក់ព័ន្ធទៅនឹងការបង្ហូរទឹកស្អុយ ឬទឹកដែលមានជាតិពុលផ្ទាល់ចូលទៅក្នុងដីតែម្ដងបង្កឱ្យមានការបំពុល ជាពិសេសទីឧស្សាហកម្មធុនធ្ងន់ដូចជា រោងចក្រផលិតសារធាតុគីមី រោងចក្រផលិតលោហធាតុ ជាដើម ហើយសកម្មភាពនេះផ្ដល់ផលប៉ះពាល់ និង បង្កការបំពុលយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។[55]

ការបំពុលដី គឺមិនសូវជាផ្ដល់ផលប៉ះពាល់ចំពោះអ្នកដែលរស់នៅក្នុងទីក្រុងឡើយ ប៉ុន្តែចំពោះប្រជាកសិករដែលរស់នៅតាមជាយក្រុង ឬខេត្តវិញអាចនឹងទទួលរងការប៉ះពាល់ខ្លាំង ដោយការបំពុលធ្វើឱ្យដីបាត់បង់នូវជីវជាតិនាំឱ្យទិន្នផលកសិកម្មមានការធ្លាក់ចុះ។ ការបំពុលដីក៏អាចបណ្ដាលឱ្យបាត់បង់ប្រព័ន្ធអេកូឡូស៊ី ហើយដីដែលត្រូវបានបំពុលដោយសារធាតុពុល និងថ្នាំសម្លាប់សត្វល្អិត ឬកត្តាចង្រៃអាចបណ្ដាលឱ្យប៉ះពាល់ដល់សុខភាពមនុស្សបង្កជាជំងឺមហារីកស្បែក

[54] ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, https://www.conserve-energy-future.com/causes-effects-solutions-of-land-pollution.php។

[55] ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, https://audiopse.blogspot.com/2017/02/blog-post_25.html?m=1។

និងបញ្ហាប្រព័ន្ធដង្ហើមរបស់មនុស្ស។ សារធាតុគីមីពុលអាចចូលក្នុងរាងកាយរបស់មនុស្សបានតាមរយៈការបរិភោគអាហារ និងបន្លែដែលត្រូវបានដាំដុះនៅក្នុងដីដែលមានសារធាតុពុល។[56]

**២.១.១.១.៣. ហេតុបង្កនាំឱ្យមានការបំពុលខ្យល់**

ការបំពុលខ្យល់ គឺជាបញ្ហាបរិស្ថានមួយដែលគេលើកយកមកពិភាក្សាច្រើនបំផុត។ ខ្យល់ពុល គឺជាខ្យល់ដែលបញ្ចេញដោយរោងចក្រឧស្សាហកម្ម មធ្យោបាយដឹកជញ្ជូនទៅក្នុងបរិយាកាសខាងក្រៅ។[57] ហើយបើយោងតាមសន្ទស្សន៍ការអនុវត្តបរិស្ថាន ប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី ១៦២ លើ ១៧៨ ប្រទេស ផ្អែកលើគុណភាពខ្យល់ នៅក្នុងឆ្នាំ២០១៤ បានបង្ហាញឱ្យដឹងថា ការបំពុលខ្យល់ គឺជាបញ្ហាគ្រោះថ្នាក់មួយដែលខ្យល់មិនបរិសុទ្ធ និងមានសារធាតុពុល គំរាមកំហែងដល់ជីវិតមនុស្ស។[58]

កំណើននៃភ្នាក់ងារបំពុល ឬសារធាតុបំពុលនៅក្នុងបរិយាកាស ធ្វើឱ្យមានការប្រែប្រួលសមាសភាពរបស់បរិយាកាស។ ជាលទ្ធផល សមត្ថភាពរបស់បរិយាកាសក្នុងការបំពេញនាទីដ៏សំខាន់សម្រាប់ជីវិតលើផែនដីត្រូវខូចខាត។ ភ្នាក់ងារបំពុលក៏ជាមូលហេតុបណ្តាលឱ្យខ្យល់មានគុណភាពមិនល្អ និងមានការខូចខាតប៉ះពាល់ដល់សុខភាពសារធារណៈ។ នៅក្នុងបរិយាកាសគេរកឃើញមានភ្នាក់ងារបំពុលចំនួនរាប់រយប្រភេទ ប៉ុន្តែមានតែសារធាតុបំពុលចំនួន ៥ ប៉ុណ្ណោះដែលត្រូវបានប្រទេសមួយចំនួនអង្កេតតាមដានជាប្រចាំ និងត្រូវបានគេប្រើជាសញ្ញាចង្អុលបង្ហាញពីគុណភាពនៃខ្យល់។ សារធាតុទាំងនោះមានដូចជា កាបូនម៉ូណូអុកស៊ីត ស្ពាន់ធ័រឌីអុកស៊ីត អាសូតអុកស៊ីតអូសូន និងភាគល្អិតអណ្តែតវិលវល់ ដែលបញ្ចេញពីរោងចក្រ យានយន្ត ឬមធ្យោបាយដឹកជញ្ជូនចំហេះអូសធ្យូង ការបាចជី ការដុតកាកសំណល់ ធូលីដី ជាដើម។ នៅពេលដែលកំហាប់របស់ឧស្ម័នទាំងនេះនៅក្នុងខ្យល់កើនឡើងលើសពីកម្រិតកំណត់ណាមួយនោះខ្យល់ត្រូវរងការបំពុល ហើយផ្តល់គ្រោះថ្នាក់ដល់ការដកដង្ហើម។[59]

ប្រទេសកម្ពុជាមិនមែនជាប្រទេសដែលរីកចម្រើនខ្លាំងក្លាខាងវិស័យឧស្សាហកម្មឡើយ។ ភាគច្រើននៃវិស័យឧស្សាហកម្ម គឺរោងចក្រកាត់ដេរ និងឧស្សាហកម្មធុនស្រាលដូចជា រោងចក្រម្ហូបអាហារ ភេសជ្ជៈ រោងចក្រវាយនភ័ណ្ឌ រោងចក្រកែច្នៃជ័រកៅស៊ូ និងឈើ ។ល។ ជាទូទៅរោងចក្រ

---

[56] ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, https://www.conserve-energy-future.com/causes-effects-solutions-of-land-pollution.php។

[57] ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, https://urbanvoicecambodia.net ។

[58] ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, https://opendevelopmentcambodia.net/km/topics/pollution-and-waste/។

[59] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៣៩។

ភាគច្រើនមានទីតាំងនៅក្នុងរាជធានីតែម្តង។ បើទោះជាចំនួនរោងចក្រនៅក្នុងប្រទេសកម្ពុជាមានតិចតួចបើប្រៀបធៀបជាមួយនឹងបណ្តាប្រទេសដទៃ ប៉ុន្តែដំណើរការនៃការផលិតបានរួមចំណែកបង្ការព្រួយបារម្ភលើបរិស្ថានជាខ្លាំង ដោយរោងចក្រទាំងនោះមួយភាគធំប្រើប្រាស់នូវបច្ចេកទេសនិងគ្រឿងចក្រចាស់ៗរួមផ្សំទាំងការមិនយកចិត្តទុកដាក់លើការបំពុលបរិស្ថានដូចជាការបំពុលខ្យល់ ហើយមិនដែលធ្វើការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន។ ដូច្នេះការបំពុលខ្យល់មកពីវិស័យឧស្សាហកម្មត្រូវបានគេចាត់ទុកថាជាបញ្ហាចំបងនៅក្នុងរាជធានីភ្នំពេញ។[60]

យានយន្ត ឬមធ្យោបាយដឹកជញ្ជូនមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការបំពុលខ្យល់ ដោយសារយានយន្តប្រើប្រាស់ប្រេងឥន្ធនៈដើម្បីដំណើរការ។ នៅពេលចំនួនប្រជាជនកាន់តែកើនជាលំដាប់នោះមធ្យោបាយដឹកជញ្ជូន និងការប្រើប្រាស់ប្រេងឥន្ធនៈក៏កាន់តែច្រើនដែរ ហើយកម្រិតនៃឧស្ម័នពុល ឬចំហេះឥន្ធនៈចេញពីយានយន្តក៏ត្រូវបានបញ្ចេញទៅក្នុងបរិយាកាសខ្ពស់ឡើងៗ។ ការបំពុលខ្យល់នៅក្នុងទីក្រុងភ្នំពេញ គឺមិនងាយនឹងជៀសផុតឡើយ ខណៈដែលយានជំនិះភាគច្រើនដែលប្រជាជនប្រើប្រាស់ជារបស់មួយទឹកចាស់ៗនាំចូលពីប្រទេសដទៃ។ ជាទូទៅយានយន្តចាស់ៗផលិតសារធាតុពុល ហើយបញ្ចេញផ្សែងពុលទៅក្នុងបរិយាកាសច្រើនជាងយានយន្តថ្មី។

លើសពីនេះទៅទៀត ការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនយានយន្តនៅក្នុងទីក្រុងបង្កឱ្យមានការស្ទះចរាចរណ៍ជាញឹកញាប់ ហើយរយៈពេលនៃការបញ្ចេញផ្សែងពុលពីយានយន្តក៏កាន់តែយូរតាមនេះផងដែរ។ ការប្រើប្រាស់ប្រេងសាំងដែលមានគុណភាពទាបដោយមានផ្ទុកសារធាតុស្ពាន់ធ័រ និងសារធាតុផ្សេងៗទៀតដែលត្រូវបានហាមឃាត់ខ្ពស់ក៏បណ្តាលឱ្យខ្យល់រងការបំពុលខ្លាំងដែរ។[61]

ធូលីដី គឺជាមូលហេតុគួរឱ្យកត់សម្គាល់មួយដែលបង្កឱ្យមានការបំពុលដល់ខ្យល់។ ភាគច្រើននៃធូលីដីនៅក្នុងទីក្រុងបណ្តាលមកពីការរៀបចំ ឬគ្រប់គ្រងគ្រឿងសំណង់ផ្សេងៗនៅពេលដឹកជញ្ជូនមិនបានត្រឹមត្រូវដូចជា ដី ខ្សាច់ ស៊ីម៉ង់ ជាដើម ហើយមានការកំពប់ ឬហៀរធ្លាក់លើផ្លូវភាយតាមខ្យល់ក៏បង្កជាការបំពុល។ ម្យ៉ាងទៀតការទុកដាក់គ្រឿងសំណង់ផ្ទាល់នៅលើផ្លូវ ក៏ជាហេតុបង្កមួយ

[60]គេហទំព័រអង្គការសហប្រជាជាតិ, *"គោលការណ៍ណែនាំស្តីពីរបាយការណ៍ជាតិសម្រាប់តំបន់ទំនាប CDS-14/15 បរិយាកាស / ការបំពុលខ្យល់"*, ទំព័រទី ១, ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, http://www.un.org ។

[61] គេហទំព័រអង្គការសហប្រជាជាតិ, *"គោលការណ៍ណែនាំស្តីពីរបាយការណ៍ជាតិសម្រាប់តំបន់ទំនាប CDS-14/15 បរិយាកាស / ការបំពុលខ្យល់"*, ទំព័រទី ១, ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, http://www.un.org ។

នៃការបំពុលខ្យល់ ព្រោះវានឹងធ្វើឱ្យផ្លូវពោរពេញទៅដោយធូលីដី ហើយប្រភពមួយផ្សេងទៀតនៃធូលីដី គឺចេញពីផ្លូវលំតូចៗមួយចំនួនដែលមិនទាន់ក្រាលថ្ម។[62]

បើទោះជា ឧស ធ្យូង ជាប្រភពដ៏ងាយសម្រាប់យកមកប្រើប្រាស់ក្នុងការចម្អិនអាហារក៏ដោយ ប៉ុន្តែការដុតវត្ថុធាតុទាំងនេះបង្កើតឱ្យមានឧស្ម័នកាបូនិច និងឧស្ម័នកាបូនអុកស៊ីតរួមទាំងឧស្ម័នពុលជាច្រើនផ្សេងទៀតដែលផ្តល់ផលប៉ះពាល់ដល់គុណភាពខ្យល់។[63]

មកទល់នឹងពេលបច្ចុប្បន្ន បើទោះជានៅក្នុងទីក្រុងមានការប្រមូលសំរាមពីសំណាក់ក្រុមហ៊ុនឯកជនក៏ដោយ ក៏នៅតែមានកន្លែងមួយចំនួនមិនទទួលបានសេវានេះឡើយ។ ដូច្នេះប្រជាជនក៏អនុវត្តន៍ទៅតាមទម្លាប់ចាស់ដោយធ្វើការដុត។ ការដុតសំរាមបានចោទជាបញ្ហាយ៉ាងធំចំពោះបរិស្ថាន ពិសេស គឺសំរាមផ្លាស្ទិកដោយសារតែផ្សែងដែលបញ្ចេញមកនោះមានផ្ទុកសារធាតុគីមីសាយភាយពាសពេញបរិយាកាសបង្កឱ្យមានការបំពុលប៉ះពាល់ដល់គុណភាពខ្យល់។ វាក៏អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាពផ្លូវដង្ហើមផងដែរ។ ម្យ៉ាងវិញទៀត នៅពេលសំរាមឆេះមិនអស់បង្កឱ្យមានភ្លើងឆេះរឹមៗមានផ្សែងច្រើនឡើងទៅក្នុងបរិយាកាស ហើយផ្សែងខ្មៅនេះជួនកាលអាចស្ថិតនៅក្នុងខ្យល់បានយូរម៉ោង។[64]

ខ្យល់ គឺជាធាតុដ៏សំខាន់មួយទ្រទ្រង់ជីវិតមនុស្ស ប្រសិនបើខ្យល់ត្រូវបានបំពុលនោះផលប៉ះពាល់នឹងកើតមានឡើងចំពោះមនុស្សគ្រប់រូប។ នៅទីក្រុងជាច្រើន កំហាប់ និងល្បាយសារធាតុបំពុលខ្យល់មានកម្រិតខ្ពស់គ្រប់គ្រាន់ដែលបណ្តាលឱ្យមានជំងឺ ហើយក្នុងចំណោមក្រុមមនុស្សដែលងាយនឹងទទួលរងគ្រោះ គឺកុមារ និងមនុស្សចាស់។ ការប្រៀបធៀបសុខភាពរបស់មនុស្សដែលរស់នៅតំបន់ដែលមានការបំពុលខ្លាំង ជាមួយនឹងសុខភាពមនុស្សរស់នៅតំបន់ដែលមានការបំពុលតិចអាចបង្ហាញឱ្យឃើញពីផលប៉ះពាល់ទៅលើសុខភាពបណ្តាលមកពីការបំពុលខ្យល់។ ជាទូទៅការប្រៀបធៀបនេះបង្ហាញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងកំរិតបំពុល និងការកើតមាននៃជំងឺដង្ហើម ហើយថែមទាំងបង្ហាញនូវទំនាក់ទំនងរវាងជំងឺមហារីកខ្លះ និងជំងឺខួរក្បាលរបស់កុមារនៅតំបន់ដែលគេប្រើប្រាស់ប្រេងសាំងមានធាតុសំណ។[65] ម្យ៉ាងវិញទៀត អង្គការសុខភាពពិភពលោក

---

[62] គេហទំព័រអង្គការសហប្រជាជាតិ, *"គោលការណ៍ណែនាំស្តីពីរបាយការណ៍ជាតិសម្រាប់តំបន់ទំនាប CDS-14/15 បរិយាកាស / ការបំពុលខ្យល់"*, ទំព័រទី ២, ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, http://www.un.org ។

[63] គេហទំព័រអង្គការសហប្រជាជាតិ, *"គោលការណ៍ណែនាំស្តីពីរបាយការណ៍ជាតិសម្រាប់តំបន់ទំនាប CDS-14/15 បរិយាកាស / ការបំពុលខ្យល់"*, ទំព័រទី ២, ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, http://www.un.org ។

[64] នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, *សៀវភៅអប់រំបំណិតជីវិតស្តីពីបរិស្ថាន* (ព្រះរាជាណាចក្រកម្ពុជា ៖ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា, ២០១៣), ៣៩។

[65] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៤០។

ថ្លែងថា មានមនុស្ស ២លាន៩សែននាក់ បានស្លាប់ជារៀងរាល់ឆ្នាំតាមរយៈការទទួលរងឥទ្ធិពលដោយផ្ទាល់ពីការបំពុលខ្យល់ ហើយមនុស្សចំនួន ១.៥លាននាក់ស្លាប់ដោយសារការបំពុលខ្យល់នៅក្នុងអាគារ។ ទីក្រុងនានានៅជុំវិញពិភពលោកដែលមានការសាយភាយខ្យល់ពុលកម្រិតខ្ពស់បង្កឱ្យកុមារមានផ្តុក ជំងឺហឺត រលាកសួត ជំងឺផ្លូវដង្ហើម និងមានអាត្រាកំណើនទារកទាប។[66]

**២.១.១.២. ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់រឹង រាវ និងសំឡេង**

សំណល់ ឬសំរាមប្រភេទណាក៏ដោយ ក៏ជាប្រភព និងជម្រកនៃមេរោគដែរ។ ហើយសំណល់មិនថារឹង ឬរាវនោះទេ គឺសុទ្ធតែកើតចេញពីការរៀបចំទុកដាក់បានត្រឹមត្រូវរបស់មនុស្ស ជាហេតុបង្កឱ្យមានការបំពុលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងចំពោះបរិស្ថានផ្ទាល់ ក៏ដូចជាសុខភាពមនុស្ស និងធ្វើឱ្យខូចសោភ័ណភាពក្នុងតំបន់ថែមទៀត។ ចំពោះសំឡេងវិញ ក៏អាចបង្កឥទ្ធិពលអវិជ្ជមានផងដែរ ប្រសិនបើសំឡេងចេញពីប្រភពណាមួយនោះលឺខ្លាំងហួសកម្រិត។

**២.១.១.២.១. ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់រឹង**

សំណល់រឹង សំដៅដល់វត្ថុរឹង ឬរូបធាតុរឹងនានា ដែលគ្មានប្រយោជន៍ លែងត្រូវការប្រើប្រាស់ ហើយត្រូវបានគេបោះចោល ឬតម្រូវឱ្យបោះបង់ចោល។[67] នៅកម្ពុជាសំណល់រឹង គឺជាបំពុលដែលឃើញជាក់ស្តែងបំផុត ហើយវាត្រូវបានបែកចែកជា២ ក្រុម គឺ សំណល់រឹងគ្មានគ្រោះថ្នាក់ និងសំណល់រឹងប្រកបដោយគ្រោះថ្នាក់។[68]

សំណល់រឹងគ្មានគ្រោះថ្នាក់ គឺមានប្រភពចេញពីលំនៅដ្ឋាន គ្រឹះស្ថានពាណិជ្ជកម្ម ផ្សារ មជ្ឈមណ្ឌលផ្គត់ផ្គង់ស្បៀងស្រស់ ឬស្ងួត សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ សួនច្បារសាធារណៈ អ្នកលក់ដូរតាមដងផ្លូវ មណ្ឌលទេសចរណ៍ ការដឹកជញ្ជូន និងកន្លែងផ្សេងៗទៀត។ សំណល់ប្រភេទនេះនឹងមិនបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់មនុស្ស សត្វ ឬរុក្ខជាតិទេ ប្រសិនបើមានការគ្រប់គ្រងបានត្រឹមត្រូវ។ សំណល់ទាំងនេះរួមមាន ក្រដាសក្រណាត់ សំណល់ផ្ទះបាយ អាហារ
ប្រអប់កាតុង ជាដើម។[69]

រីឯសំណល់ប្រកបដោយគ្រោះថ្នាក់ គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជម្ងឺមហារីកនិងជម្ងឺឆ្លង ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ឬមានផ្ទុកនូវសារធាតុគីមីដទៃទៀតដែល

---

[66] នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, *សៀវភៅអប់រំបំណិតជីវិតស្តីពីបរិស្ថាន (*ព្រះរាជាណាចក្រកម្ពុជា ៖ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា, ២០១៣), ៣៨។

[67] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ៣៦អនក្រ/បក, ២៧ មេសា ១៩៩៩, មាត្រា៣។

[68] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៧៧។

[69] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៧៧។

អាចបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញ ដល់រុក្ខជាតិ និងបរិស្ថាន។[70] ជាទូទៅសំណល់ប្រភេទនេះ គឺមានប្រភពចេញពីឧស្សាហកម្ម ដូចជារោងចក្រធ្វើអាគុយ រោងចក្រធ្វើស័ង្កសី រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត ឧស្សាហកម្ម ថ្នាំពេទ្យ ឧស្សាហកម្មថ្នាំលាប ឬរាល់រោងចក្រ ឧស្សាហកម្ម សហគ្រាសដែលប្រើប្រាស់សារធាតុគីមីច្រើន មន្ទីរពេទ្យ និងទីសត្តឃាត ជាដើម។ សំណល់ប្រភេទនេះ គឺមានផ្ទុកទៅដោយសារធាតុគីមី និងសារធាតុប្រកបទៅដោយគ្រោះថ្នាក់ដែលទាមទារឱ្យមាននូវវិធានការពិសេសក្នុងការទុកដាក់បានត្រឹមត្រូវ។ សំណល់ទាំងនេះរួមមាន ម្ជុលចាក់ថ្នាំ សំណល់លោហៈ ធុងថ្នាំសំលាប់សត្វល្អិត អាគុយចាស់ៗ និងថ្មពិល ។[71]

ទោះជាយ៉ាងណាក្តី សំណល់នៅតាមលំនៅដ្ឋានក៏អាចមានសារធាតុប្រកបដោយគ្រោះថ្នាក់ដែរ ប៉ុន្តែគ្រាន់តែមានកម្រិតតិចតួច។ រីឯវិស័យកសិកម្មវិញ ដោយសារបច្ចេកវិទ្យារបស់យើងនៅមានកម្រិតទាប កសិករភាគច្រើនបានប្រើប្រាស់ ថ្នាំសម្លាប់សត្វល្អិតដែលមានជាតិពុលខ្លាំង និងប្រើប្រាស់ជាតិគីមីដើម្បីបង្កើនទិន្នផលដំណាំ ដូច្នេះសារធាតុប្រកបដោយ គ្រោះថ្នាក់មួយចំនួនក៏ត្រូវបានកើតឡើងតាមរយៈវិស័យនេះផងដែរ។

កំណើននៃចំនួនប្រជាជន កំណើនកំរិតជីវភាពរស់នៅ កំណើននគរូបនីយកម្ម និងឧស្សាហកម្ម បានបង្កើននូវបរិមាណនៃសំណល់រឹងកាន់តែច្រើនឡើងៗ។ ការគ្រប់គ្រងការប្រមូល និងដឹកជញ្ជូនសំណល់រឹងនៅភ្នំពេញ គឺជាបញ្ហាដ៏គួរឱ្យព្រួយបារម្ភរបស់សាលាក្រុង ហើយក៏ជាកង្វល់របស់ក្រសួងបរិស្ថានដែលកំពុងខិតខំតាក់តែងច្បាប់សម្រាប់តាមដានអង្កេត និងត្រួតពិនិត្យការបំពុលឱ្យមានប្រសិទ្ធភាព។[72] ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវទេនោះ សំណល់រឹង គឺអាចជះនូវឥទ្ធិពលអវិជ្ជមានប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសោភ័ណភាពទីក្រុង បរិស្ថាន សង្គមជាតិ សុខភាពមនុស្ស សត្វ និងរុក្ខជាតិ។ សំណល់រឹងជាប្រភព និងទីជម្រកនៃពពួកមេរោគឆ្លង ព្រមទាំងសត្វល្អិតចង្រៃជាច្រើន។ ទោះជាយ៉ាងណា សំណល់រឹងមួយចំនួនដែលមិនបង្កគ្រោះថ្នាក់ដូចជា សំណល់ផ្ទះបាយ ក្រដាសកាតុង ក្រណាត់ កែវ ផ្លាស្ទិក ជាដើមនៅពេលមិនទទួលបានការទុកដាក់ត្រឹមត្រូវ ឬត្រូវបានបោះចោលសំណល់រាយប៉ាយ គឺគ្រាន់តែបង្កឱ្យមានក្លិនស្អុយ ឬកកស្ទះប្រព័ន្ធលូ តាមរយៈការហូរនាំដោយទឹកភ្លៀងប៉ះពាល់ដល់សោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈប៉ុណ្ណោះ។ ប៉ុន្តែចំពោះសំណល់រឹងប្រកបដោយគ្រោះថ្នាក់ដែលមានផ្ទុកសារធាតុពុលវិញ គឺអាចជះឥទ្ធិពលអាក្រក់

---

[70] ចូលមើលលើកចុងក្រោយ ២០ ឧសភា ២០១៨, http://www.healthcambodia.com/p9670/។

[71] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៧៧។

[72] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី,* កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៧៥។

ដល់សុខភាពប្រជាជនដូចជាប៉ះពាល់ដល់ផ្លូវដង្ហើម កើតមានជម្ងឺសើរស្បែក និងជម្ងឺឆ្លងនានា (បាក់តេរី ឬវីរុសដែលបង្កឱ្យមានជម្ងឺជីវសាស្ត្រដូចជាប៉ារ៉ាសិត និងបាក់តេរីទាក់ទងនឹងជម្ងឺពោះវៀន និងក្រពះ) ពិសេសចំពោះអ្នករើសអេតចាយ ឬអ្នកក្រីក្ររស់នៅជុំវិញទីលានចាក់សំណល់រឹង គឺងាយនឹងទទួលរងគ្រោះថ្នាក់តាមរយៈការមុត ឬប៉ះពាល់សំណល់ដោយផ្ទាល់ ខណៈដែលកម្រិតនៃការយល់ដឹងពីអនាម័យ និងសុខភាពរបស់ពួកគេនៅមានកម្រិត។ លើសពីនេះទៅទៀត ទឹកសំអុយដែលចេញពីសំណល់នោះមានផ្ទុកពេញទៅដោយសារធាតុគីមីពុលនៅពេលជ្រាបចូលទៅក្នុងដីក៏អាចធ្វើឱ្យប៉ះពាល់ដល់គុណភាពដី ទឹក និងទឹកក្រោមដីបង្កជាការបំពុលទឹក និងដីផងដែរ។[73]

### ២.១.១.២.២. ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់រាវ

សំណល់រាវ គឺសំដៅលើវត្ថុរាវដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬបណ្តាញលូ ទោះបីជាបាន ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី។[74] មិនខុសពីការបំពុលផ្សេងទៀតនោះទេ ប្រសិនជាគ្មានការគ្រប់គ្រងបានត្រឹមត្រូវ សំណល់រាវប្រាកដជានឹងបង្កឱ្យកើតមានឥទ្ធិពលអវិជ្ជមានគួរឲ្យព្រួយបារម្ភទៅលើសុខភាពសាធារណៈ សោភ័ណភាពនៃទីក្រុង និងបរិស្ថាន។

សំណល់រាវដែលបញ្ចេញពីគ្រប់ប្រភពដូចជា លំនៅដ្ឋាន ឧស្សាហកម្ម មន្ទីរពេទ្យ ឬ អាចជាសំណល់សល់ពីការធ្វើពាណិជ្ជកម្ម គឺសុទ្ធតែជាហេតុបង្កនាំឲ្យមានការបំពុលបរិស្ថាន។ សំណល់ទាំងនោះអាចជា សំណល់ពីការបន្ទោរបង់ ការបោកខោអាវ ការលាងបន្លែផ្លែឈើ ត្រីសាច់ សំណល់រាវចេញពីការបោកសម្អាតក្រណាត់នៃរោងចក្រកាត់ដេរសម្លៀកបំពាក់ សំណល់ដែលសល់មកពីឧស្សាហកម្មគីមីដូចជា ឧស្សាហកម្មប្រេង ឧស្សាហកម្មតម្បាញ ឧស្សាហកម្មលោហធាតុ និងសំណល់ផ្សេងៗសល់ពីការវះកាត់រួមមានឈាម និងទឹករំអិល ជាដើម។[75]

មិនថាតិច ឬច្រើន កាលណាមានហេតុបង្ក នោះផលប៉ះពាល់ក៏នឹងកើតមាន។ ប្រសិនបើសំណល់រាវមិនទទួលបាននូវការគ្រប់គ្រងត្រឹមត្រូវទេនោះការបំពុល ក៏ដូចជាផលប៉ះពាល់ជាច្រើននឹងកើតមានឡើងចំពោះសោភ័ណភាព បរិស្ថាន សុខភាពមនុស្ស សត្វ រុក្ខជាតិ។[76] ការចាក់ចោលសំរាមមិនបានត្រឹមត្រូវបង្កផលប៉ះពាល់ចំពោះមនុស្សផ្ទាល់ ដោយបង្កើតជាប្រភពដ៏ចម្បងដល់ការរីករាលដាលនៃជម្ងឺជាច្រើនប្រភេទដូចជា ជម្ងឺគ្រុនពោះវៀន គ្រុនចាញ់ រាគរូស ជាដើម។ មនុស្សអាចឆ្លងជំងឺទាំងនេះតាមរយៈការបរិភោគ ឬប្រើប្រាស់ទឹកដែលទទួលរងការបំពុល សត្វរុយ

---

[73] ចូលមើលលើកចុងក្រោយ ២៥ ឧសភា ២០១៨, http://www.healthcambodia.com/p9842/។

[74] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩, មាត្រា៣។

[75] ចូលមើលលើកចុងក្រោយ ២៥ ឧសភា ២០១៨, http://www.healthcambodia.com/p7901/។

[76] ចូលមើលលើកចុងក្រោយ ២៥ ឧសភា ២០១៨, http://www.healthcambodia.com/p7901/។

និងភ្នាក់ងារចម្លងមេរោគផ្សេងៗទៀត ដូចជាសត្វជ្រូក ឆ្មា និងសត្វពាហនៈដែលដើរលុកលុយក្នុងគំនរសំរាម។ ចំពោះសារធាតុគីមីផ្សេងៗទៀតដែលមានប្រភពមកពីសំណល់ឧស្សាហកម្ម និងសំណល់ទីក្រុង គឺអាចចូលទៅក្នុងខ្លួនមនុស្សបានតាមរយៈការដកដង្ហើម ការបរិភោគ ឬការប៉ះពាល់ដោយផ្ទាល់។ ប្រសិនបើមានការជ្រាបចូលនូវមេរោគដែលកើតចេញពីសំរាម ឬកាកសំណល់ទៅក្នុងខ្លួនច្រើនមនុស្សអាចនឹងរងគ្រោះដល់ថ្នាក់បាត់បង់ជីវិតបាន។ ទោះបីជាការស្រូបចូលមានបរិមាណចំនួនតិចតួចក៏ដោយក៏អាចបណ្តាលឱ្យមានផលមិនល្អចំពោះសុខភាពបានដែរ។ រីឯផលប៉ះពាល់នៃការបំពុលដោយសំណល់រាវដោយប្រយោលវិញ គឺការបាត់បង់នូវធនធានទឹក ដី ខ្យល់ ដែលជាតម្រូវការចាំបាច់បំផុតសម្រាប់ទ្រទ្រង់ដល់ការរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិ ។

**២.១.១.២.៣. ហេតុបង្កនាំឱ្យមានការបំពុលដោយសំឡេង**

សំឡេងចរាចរណ៍ សំឡេងយន្តហោះ សំឡេងរ៉ារថភ្លើង សំឡេងតន្ត្រី ឧបករណ៍បំពងសំឡេង និងម៉ាស៊ីននៅក្នុងរោងចក្រជាដើម គឺសុទ្ធតែជាប្រភពនៃការបំពុលដោយសំឡេង។ បើទោះជាមនុស្សភាគច្រើនគិតថា ការបំពុលដោយសំឡេងមិនសូវជាប៉ះពាល់ក៏ដោយ ក៏តាមពិតទៅវាអាចជះឥទ្ធិពលអាក្រក់ខ្លាំងចំពោះជីវិតរស់នៅប្រចាំថ្ងៃមនុស្សគ្រប់គ្នាបាន។

ការបំពុលដោយប្រភពចល័ត និងអចល័ត គឺជាប្រភពនៃការបំពុលដោយសំឡេង។ ការបំពុលដោយប្រភពចល័ត សំដៅលើប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ ពោល គឺមិនឈប់ស្ងៀមនៅនឹងមួយកន្លែង ឬជាក់លាក់ ដែលសំដៅលើការបំពុលដោយសំឡេងចេញពីយានយន្តនាវាដឹកជញ្ជូន យន្តហោះ គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។ ខណៈដែលការបំពុលដោយប្រភពអចល័តសំដៅលើប្រភពបំពុលដែលចេញមកពីទីតាំងជាក់លាក់អចិន្ត្រៃយ៍មួយកន្លែង អាចជា រោងចក្រ សហគ្រាស កន្លែងកំសាន្ត ឬក្លឹបកំសាន្ត កន្លែងឈូសឈើ ផ្សារដែក ការដ្ឋានសំណង់ ជាដើម។[77] ជាក់ស្តែងនៅក្នុងខណ្ឌចំការមន គឺមានក្លឹបកំសាន្ត ឬកន្លែងខារ៉ាអូខេ រោងចក្រជាច្រើន ដូច្នេះអ្នកដែលរស់នៅក្នុងតំបន់នេះអាចត្រូវទទួលរងការបំពុលដោយសំឡេង។

**រូបទី២៖ ផលប៉ះពាល់នៃការបំពុលដោយសំឡេង**




[77] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ/បក, ៦ កក្កដា ២០០០, មាត្រា៣។

| ផលប៉ះពាល់នៃការបំពុលដោយសំឡេង | |
|---|---|
| | ហ៊ឹងត្រចៀក |
| | មានជំងឺលើសសម្ពាធឈាម |
| | បំផ្លាញដល់ការចងចាំ |

(ប្រភព៖ www.bayonweb.com)

រូបខាងលើមានផលប៉ះពាល់បី ដែលជាចំណុចសំខាន់នោះ គឺបញ្ហាហ៊ឹងត្រចៀក មានជំងឺលើសសម្ពាធឈាម និងបំផ្លាញដល់ការចងចាំ។ ដោយសារតែការបំពុលដោយសំឡេងមានមនុស្សមួយចំនួន ចាប់ផ្តើមជួបប្រទះបញ្ហាលាន់លឺសំឡេងហ៊ឹងរំខានជាប់ក្នុងត្រចៀកជានិច្ច ហើយបញ្ហានេះអាចបណ្តាលឱ្យបាត់បង់លទ្ធភាពនៃការស្តាប់។

ទន្ទឹមនឹងនេះក៏អាចកើតមានជំងឺលើសសម្ពាធឈាម ដោយសារវាមានឥទ្ធិពលអាចនឹងធ្វើឱ្យមនុស្សឈានទៅរកការវិវត្តន៍ជាមាននូវជម្ងឺលើសសម្ពាធឈាម និង បញ្ហាផ្សេងៗនៃបេះដូងដែលបញ្ជាក់ថា ការបំពុលប្រភេទនេះ ក៏អាចធ្វើឱ្យមនុស្សមួយចំនួនស្លាប់បានដែរ ។ លើសពីនេះការបំពុលដោយសំឡេងក៏អាចបំផ្លាញដល់ការចងចាំ និងសមត្ថភាពនៃញាណដឹងរបស់មនុស្សម្នាក់ៗជាពិសេស គឺកុមារតែម្តង។

### ២.១.២. យន្តការក្នុងការរៀបចំសោភ័ណភាពក្នុងខណ្ឌចំការមន

ការលើកកម្ពស់ទៅលើការរក្សានូវសោភ័ណភាព គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលរាជធានីទាំងមូល ក៏ដូចជាក្នុងខណ្ឌមិនគួរមើលរំលង ក៏ព្រោះសោភ័ណភាព គឺជាភាពទាក់ទាញម៉្យាងជួយធ្វើឱ្យរាជធានី ឬខណ្ឌមានទេសភាពស្រស់ស្អាត និងជាទីគួរឱ្យចង់រស់នៅ។ ទាក់ទងទៅនឹងការធ្វើឱ្យសោភ័ណភាពកាន់តែល្អប្រសើរឡើងនោះ វាមិនអាចខ្វះបានឡើយនូវកត្តាសំខាន់ ២ គឺ បណ្តាញខៀវ និងបណ្តាញបៃតង។

#### ២.១.២.១. ការរៀបចំបណ្តាញខៀវ និងបណ្តាញបៃតង

ការរៀបចំបណ្តាញខៀវ និង បណ្តាញបៃតង គឺជាផែនការយុទ្ធសាស្រ្តមួយ ដើម្បីស្តារការ

អភិវឌ្ឍទាំងនៅកណ្តាលក្រុង និងនៅជាយក្រុងឱ្យមានភាពស្រស់បំព្រងតាមរយៈផ្ទៃទឹក និងដើម

ឈើ។[78]

### ២.១.២.១.១. បណ្តាញខៀវ

បណ្តាញខៀវ គឺជាធាតុមួយសម្រាប់ធ្វើការកែលម្អសោភ័ណភាពតាមរយៈការកែច្នៃទឹក។ បើក្រឡេកមើលទៅតាមទីតាំងភូមិសាស្ត្រនៃរាជធានីភ្នំពេញទាំងមូលនោះនឹងអាចឃើញថា ក្រៅពីទន្លេក៏នៅមានបឹង ស្ទឹង ជាច្រើនទៀត។ បឹងជាច្រើនដែលហ៊ុំព័ទ្ធនៅជុំវិញរាជធានី គឺមានសារៈសំខាន់ណាស់ដែលផ្ទៃទឹកត្រូវរក្សាទុក ដើម្បីការពារទប់ស្កាត់នូវបញ្ហាហានិភ័យនៃគ្រោះទឹកជំនន់។ ម្យ៉ាងវិញទៀត ដោយសារតែភាពទន់ខ្សោយនៃប្រព័ន្ធលូក្នុងរាជធានីដែលមិនអាចហូរទាន់ពេលនោះ បានធ្វើឱ្យបឹងប្រែជាអាងស្តុកនូវទឹកភ្លៀងទាំងឡាយបណ្តោះអាសន្នផងដែរ។ ក្រៅពីនេះពួកវាបានផ្តល់នូវសម្រស់ផ្ទៃទឹកពណ៌ខៀវបន្ថែមលើទេសភាពបៃតង ធ្វើឱ្យទីក្រុងមានភាពទាក់ទាញបែបធម្មជាតិ។[79] ជាក់ស្តែងរដ្ឋបាលខណ្ឌចំការមនបានព្យាយាមទប់ស្កាត់នូវរាល់សកម្មភាពចាក់ដីលុបបឹងធម្មជាតិបឹងត្របែក ដើម្បីបញ្ចៀសការជន់លិចផ្លូវមួយចំនួននៅពេលមានភ្លៀងធ្លាក់ខ្លាំងម្តងៗ។[80]

### ២.១.២.១.២. បណ្តាញបៃតង

បណ្តាញបៃតង គឺមានតួនាទីអមជាមួយនឹងបណ្តាញខៀវដើម្បីលម្អរំលេចនូវសម្រស់ធម្មជាតិយ៉ាងស្រស់បំព្រងរបស់រាជធានី ក៏ដូចជាចូលរួមក្នុងតំបន់កណ្តាលក្រុងដើម្បីលើកស្ទួយទេសភាពបៃតងដែលក្នុងនោះមានការពង្រីកដាំដើមឈើជាជួរៗតាមបណ្តាបណ្តោយវិថី សួនច្បារ និងទីលានលម្ហែកាយ ជាដើម ដោយការដាំនេះតម្រូវទៅតាមប្រភេទនីមួយនៃផ្លូវ ពោល គឺសមាមាត្រទៅនឹងទំហំផ្លូវ។[81] ការជំរុញឱ្យមានការពង្រីក និងរក្សាតំបន់បៃតង គឺសំខាន់ណាស់ដោយវាមិនត្រឹមតែជួយបន្ថែមសោភ័ណភាពរបស់រាជធានី ឬ ទីក្រុងឱ្យមានភាពកាន់តែទាក់ទាញប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប្រសើរចំពោះបរិស្ថាន និងសុខភាពផងដែរដោយដើមឈើ ឬតំបន់បៃតងជួយស្រូបយកឧស្ម័នពុលកាបូនិច ផ្តល់អារម្មណ៍ស្រស់ស្រាយ កាត់បន្ថយភាពស្មុគស្មាញ ងាយស្រួលដកដង្ហើមដែលធ្វើឱ្យអ្នករស់នៅជិតតំបន់នេះមានអារម្មណ៍ប្រសើរបំផុត។

ជាក់ស្តែងខណ្ឌចំការមនមានសួនច្បារជាច្រើនដែលក្នុងចំណោមសួនច្បារទាំងនោះសាលារាជធានីភ្នំពេញបានធ្វើការជួសជុលកែលម្អសួនច្បាររង្វង់មូលផ្សារដើមថ្កូវមានទីតាំងប្រសព្វរវាងផ្លូវ

[78] អ៊ុន សកក្កដា, "នីតិនគរូបនីយវិទ្យា" (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ៥០។

[79] អ៊ុន សកក្កដា, "នីតិនគរូបនីយវិទ្យា" (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ៥២។

[80] ខណ្ឌចំការមន, *កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន*, ឆ្នាំ២០១៨-២០២០, ១៧។

[81] អ៊ុន សកក្កដា, "នីតិនគរូបនីយវិទ្យា" (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ៥៣។

លេខ ៤៣០ ផ្លូវលេខ ៤៨៨ និងផ្លូវលេខ ១៦៣ ក្នុងខណ្ឌចំការមនដើម្បីលើកកម្ពស់សោភ័ណភាពរាជធានីឲ្យបានល្អប្រសើរថែមទៀត។[82]

### ២.១.២.២. វិធានការការពារ និងបញ្ហាប្រឈមក្នុងការអភិវឌ្ឍបរិស្ថាន

#### ២.១.២.២.១.វិធានការការពារពាក់ពន្ធ័នឹងបរិស្ថាន

តាមរយៈការចាត់វិធានការការពារដ៏ត្រឹមត្រូវ និងអនុវត្តន៍យ៉ាងសកម្មទើបធ្វើឱ្យខណ្ឌចំការមនសម្រេចបាននូវសមិទ្ធិផលល្អប្រសើរគួរឱ្យកត់សម្គាល់ ដោយអាជ្ញាធរខណ្ឌបានចុះទៅត្រួតពិនិត្យផ្ទាល់ ក៏ដូចជាសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធស្វែងរកដំណោះស្រាយភ្លាមៗ ចំពោះបញ្ហាដែលបង្កឱ្យប៉ះពាល់ដល់សោភ័ណភាព ឬការបំពុលបរិស្ថានផ្សេងៗ។ វិធានការដែលបានចុះអនុវត្តន៍ទាំងនោះមានដូចជា អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីការថែរក្សាបរិស្ថាន ការវេចខ្ចប់ និងការទុកដាក់សំរាមការរៀបចំប្រព័ន្ធបង្ហូរលូទឹកស្អុយ ដោយធ្វើការជួសជុលលូដែលមានសភាពចាស់ទ្រុឌទ្រោមឡើងវិញ និងស្តារមាត់លូ ប្តូរប្រព័ន្ធលូថ្មី រៀបចំ ដាក់លូថ្មីមានមុខកាត់ធំការទប់ស្កាត់រាល់សកម្មភាពចាក់ដីលុបបឹងធម្មជាតិបឹងត្របែក[83] ធ្វើការអប់រំផ្សព្វផ្សាយពីបរិស្ថានដល់ប្រជាពលរដ្ឋឲ្យបានដឹង និងចុះធ្វើការពន្យល់ណែនាំអំពីការវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងញែកសំរាមឱ្យបានល្អប្រសើរ។[84]

ទោះបីជាមានវិធានការការពារ និងមានការចុះត្រួតពិនិត្យសកម្មយ៉ាងណា ក៏បញ្ហានៃការបំពុលបរិស្ថាននៅតែឃើញកើតមាន ដែលបណ្តាលមកពីកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋខណៈដែលអ្នកខ្លះទៀតមិនព្រមឈប់ប្រព្រឹត្ត បើទោះជាបានដឹងពីផលប៉ះពាល់អវិជ្ជមាននៃបរិស្ថានធ្វើឱ្យបាត់បង់នូវសោភ័ណភាពក្នុងខណ្ឌ ឬតំបន់ដែលពួកគេកំពុងរស់នៅហើយក៏ដោយ។

#### ២.១.២.២.២. បញ្ហាប្រឈមក្នុងការអភិវឌ្ឍបរិស្ថាន

បញ្ហាប្រឈមដល់ការអភិវឌ្ឍមានដូចជា ប្រជាពលរដ្ឋមិនបានយកចិត្តទុកដាក់ ចំពោះការ
វេចខ្ចប់សំរាមឲ្យបានត្រឹមត្រូវ ប្រព័ន្ធលូទឹកមិនទាន់ធ្វើការរៀបចំបានល្អដែលបណ្តាលឱ្យមានការកកស្ទះរួមទាំងបញ្ហាលិចផ្លូវនៅពេលមានភ្លៀងធ្លាក់ម្តងៗ ប្រឡាយទឹកបឹងត្របែកចរន្តទឹកហូរពុំទាន់លំនៅដ្ឋានច្រើនគ្មានដេប៉ូសំរាម (ផ្ទះជាន់លើគ្នា) ប្រជាពលរដ្ឋទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់ក្រុមហ៊ុនស៊ីនទ្រីមកយកមិនទៀងទាត់ និងវិធានការរឿងផាកពិន័យនៅមិនទាន់ខ្លាំងក្លា។[85]

---

[82] ចូលមើលលើកចុងក្រោយ ២៨ ឧសភា ២០១៨, https://urbanvoicecambodia.net/maps/reports/view/9749។

[83] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ៣១។

[84] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ៥៥។

[85] ខណ្ឌចំការមន, *ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន*, ឆ្នាំ២០១៥-២០១៩, ២៦។

## ២.២. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលបរិស្ថាន

ក្រោយពីបានដឹងពីហេតុបង្ក និងផលប៉ះពាល់មួយចំនួនដូចរៀបរាប់ខាងលើហើយនោះ ដំណោះស្រាយ គឺជាកត្តាមួយដ៏ចាំបាច់ក្នុងការធានាបាននូវនិរន្តភាពនៃសោភ័ណភាពល្អ បរិស្ថានស្អាត។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិធានការដោះស្រាយពាក់ព័ន្ធទៅនឹងបញ្ហាបរិស្ថាន និងធនធានធម្មជាតិជារួមត្រូវបានធ្លាក់ទៅលើសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល និងក្រសួងបរិស្ថានដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ[86] ហើយវិធានការទាំងនោះត្រូវប្រកបទៅដោយនិរន្តភាព និងស្ថិរភាព។[87] ការការពារបរិស្ថាន និងដំណោះស្រាយទាក់ទងទៅនឹងការបំពុលបរិស្ថានត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ១៨ វិច្ឆិកា ១៩៩៦ ។ ច្បាប់នេះមានគោលដៅជារួមដូចតទៅ ៖ ការពារ លើកកំពស់គុណភាពដល់បរិស្ថាន និងសុខភាពពលរដ្ឋតាមរយៈការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យនូវរាល់ការបំពុល វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គំរោងដែលបានស្នើរឡើង ព្រមទាំងធានាឱ្យមានការអភិរក្សការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តភាព និងស្ថិរភាពនៃធនធានធម្មជាតិ។ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ នេះក៏បានលើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ហើយបង្ក្រាបនូវរាល់អំពីទាំងឡាយណាដែលធ្វើឱ្យបរិស្ថានទទួលរងផលប៉ះពាល់។[88]

គួរបញ្ជាក់ផងដែរថា ក្រៅពីស្ថាប័នរដ្ឋហើយនោះ សាធារណៈជន ក៏ជាបុគ្គលសំខាន់ដែលគួរចូលរួមក្នុងការដោះស្រាយនូវបញ្ហាបរិស្ថានក៏ដូចជាទទួលបាននូវពត៌មានផ្សេងៗពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការជំរុញលើកទឹកចិត្តពីសំណាក់ក្រសួងបរិស្ថាន។[89]

[86] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ នស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦, មាត្រា ២។

[87] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ នស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦, មាត្រា ៣។

[88] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ នស/រកម/១២៩៦/៣៦, ២៤ ធ្នូ១៩៩៦, មាត្រា ១។

[89] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ នស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦, មាត្រា ១៦។

### ២.២.១. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលទឹក ដី និងខ្យល់

#### ២.២.១.១. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលទឹក

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងឈានដល់ដំណោះស្រាយក្រសួងបរិស្ថានមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវ និងវាស់គុណភាពនៃទឹក និងស្វែងរកប្រភពនៃការបំពុលមុនការចេញនូវដំណោះស្រាយពាក់ព័ន្ធ។[90] ការត្រួតពិនិត្យទៅលើការបំពុលទឹក គឺទប់ស្កាត់ និងកាត់បន្ថយនូវការបំពុល ដើម្បីការពារដល់សុខភាពមនុស្ស។[91] ការត្រួតពិនិត្យ និងស្វែងរករាល់ប្រភពបំពុល ក៏ដូចជាសកម្មភាពទាំងឡាយណាដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ គឺជាដំណោះស្រាយចំបងមួយដែលប្រសើរបំផុតដើម្បីធ្វើឱ្យបរិស្ថានទឹកជៀសផុតពីការបំពុល ហើយជាពិសេស គឺជួយកែលម្អបញ្ហាសោភ័ណភាពនិងប្រកបទៅដោយផាសុកភាពល្អក្នុងការរស់នៅប្រចាំថ្ងៃ។ លើសពីនេះទៅទៀត ក្រសួងបរិស្ថានត្រូវរៀបចំកំណត់កម្រិតស្តង់ដាបរិមាណនៃការបញ្ចេញសំណល់រាវ ឬសារធាតុគីមីពុលគ្រប់ប្រភេទមុននឹងអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា។[92]

ដើម្បីសម្អាត ក៏ដូចជារក្សាបាននូវអនាម័យល្អ បរិស្ថានស្អាត និងសោភ័ណ្ឌក្នុងទីក្រុង ការយល់ដឹងចូលរួមរបស់សាធារណៈជន គឺជាកត្តាចាំបាច់បំផុតដូចគ្នា។ ដូច្នេះគួរជំរុញឱ្យមានការចូលរួមពីសំណាក់សាធារណៈជនគ្រប់រូបតាមរយៈជាលក្ខណៈអប់រំ ផ្សព្វផ្សាយលើប្រព័ន្ធផ្សព្វផ្សាយនានាដូចជា វិទ្យុ ទូរទស្សន៍ និងការបង្កើតទិវាបរិស្ថាន។

ម្យ៉ាងទៀត គ្រប់រោងចក្រ សហគ្រាស ឬក្រុមហ៊ុនគួរអនុវត្តន៍ការគ្រប់គ្រងកាកសំណល់ឱ្យបានល្អត្រឹមត្រូវ ដោយមិនត្រូវបង្ហូរចូលទៅក្នុងប្រឡាយទឹកតាមរយៈការបង្កើតអាងស្តុកទុកកាកសំណល់រាវរបស់ខ្លួន។ ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ត្រូវរៀបចំផែនការឱ្យបានច្បាស់លាស់សំរាប់គ្រប់គ្រងសំណល់គ្រប់ប្រភេទ។ បើទោះជាបច្ចុប្បន្ននេះ ការចែងបទបញ្ញត្តិបានចេញរួចទៅហើយក៏ពិតមែន ប៉ុន្តែមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ។ ហេតុដូច្នេះស្ថាប័នដែលត្រួតពិនិត្យ និងគ្រប់ម្ចាស់នៃប្រភពបំពុលទឹកត្រូវចូលរួមគោរព និងពង្រឹកច្បាប់នោះឱ្យបានកាន់តែប្រសើរឡើង។[93]

---

[90] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩, មាត្រា១៨ និង មាត្រា១៩។

[91] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩, មាត្រា១។

[92] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩, មាត្រា២។

[93] ចូលមើលលើកចុងក្រោយ ៣០ ឧសភា ២០១៨, http://www.healthcambodia.com/p6241/។

ការកើនឡើងនៃការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងជីកសិកម្មគួរតែត្រូវបានត្រួតពិនិត្យ និងបង្កើតច្បាប់គ្រប់គ្រងលើការស្តុកទុក ការវេចខ្ចប់ ការលក់ដូរ ការដាក់ផ្លាកយីហោ ការប្រើប្រាស់ និងការចាក់ចោល ក៏ព្រោះបង្កការបំពុលដល់បរិស្ថានខ្លាំងណាស់។ លើសពីនេះទៅទៀត ប្រជាជនគួរទទួលបានការអប់រំស្តីពីការប្រើប្រាស់ថ្នាំសំលាប់កត្តាចង្រៃដែលមានប្រភពពីធម្មជាតិជំនួសវិញ។[94]

### ២.២.១.២. វិធានការដោះស្រាយចំពោះការបំពុលដី

យើងអាចការពារដីពីការបំពុល ដោយការប្រើប្រាស់សម្ភារៈតិចតួច ប្រើប្រាស់វត្ថុដែលឆាប់រលាយ និងសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញបាន។[95] ម្យ៉ាងទៀតហេតុបង្កដែលនាំឱ្យមានការបំពុលដី គឺបណ្តាលពីកត្តាសំរាម កត្តាឧស្សាហកម្ម និងកត្តាកសិកម្ម ដូច្នេះការអប់រំប្រជាជនអប់រំដល់ប្រជាជនឱ្យយល់ដឹងអំពី ផលប៉ះពាល់នៃការបំពុលដី ការទុកដាក់វេចខ្ចប់សំរាមឱ្យបានត្រឹមត្រូវគោលការណ៍នៃការកាត់បន្ថយ ការកែច្នៃ និងការប្រើប្រាស់ឡើងវិញ ការកាត់បន្ថយការប្រើប្រើថ្នាំសម្លាប់សត្វល្អិត ឬកត្តាចង្រៃ កម្រិតនៃការប្រើប្រាស់ជីក្នុងសកម្មភាពកសិកម្ម ពិតជាសំខាន់ណាស់ក្នុងការកាត់បន្ថយបាននូវបញ្ហានៃការបំពុលដី។[96]

### ២.២.១.៣. វិធានការដោះស្រាយចំពោះការបំពុលខ្យល់

ការគ្រប់គ្រង និងចាត់ចែងចំពោះបញ្ហានៃការបំពុលខ្យល់ គឺស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថានដែលមានតួនាទីក្នុងការត្រួតពិនិត្យ និងអនុញ្ញាតលើការបញ្ចេញខ្យល់ដែលអាចផ្តល់តទ្ធិពលប៉ះពាល់ជាអវិជ្ជមានចំពោះបរិស្ថាន ដោយយោងតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់និងការរំខានដោយសំឡេង ចុះថ្ងៃទី ១០ កក្កដា ២០០០ ។ គុណភាពរបស់ខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានត្រួតពិនិត្យ និងតាមដានជាប្រចាំដោយក្រសួងបរិស្ថាន។[97]

ការរារាំងចំពោះរាល់ការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាសដែលមិនឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារ គឺជាកត្តាចំបងមួយក្នុងការកាត់បន្ថយការបំពុលខ្យល់។ ផ្សែងដែលបញ្ចេញពីឡដុត រោងចក្រផលិតលោហធាតុ រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្អុយ រោងចក្រផលិ

[94] ណូអែល អូប្រាយែន, *បរិស្ថានសៀវភៅជំនួយស្មារតី*, កែសម្រួល ទិន ពន្លក (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥), ២៣៦។

[95] ចូលមើលលើកចុងក្រោយ ៣០ ឧសភា ២០១៨, https://audiopse.blogspot.com/2017/02/blog-post_25.html?m=1។

[96] ចូលមើលលើកចុងក្រោយ ៣០ ឧសភា ២០១៨, https://www.conserve-energy-future.com/causes-effects-solutions-of-land-pollution.php។

[97] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ/បក, ៦ កក្កដា ២០០០, មាត្រា២៦។

តបេតុង សារធាតុគីមី និងសារធាតុបំពុលដែលបញ្ចេញពីប្រភពផ្សេងៗទៀតដែលអាចប៉ះពាល់ដល់ខ្យល់បណ្តាលឱ្យទទួលរងនូវការបំពុល គឺត្រូវតែមានការកម្រិតកំណត់យ៉ាងត្រឹមត្រូវ ហើយច្បាស់លាស់ជាទីបំផុតមុននឹងអនុញ្ញាតឱ្យបញ្ចេញទៅក្នុងបរិយាកាស។[98] ឧទាហរណ៍ ៖ រោងចក្រផលិតស៊ីម៉ង់ត៍ កំបោរនិងថ្មស្អុយកម្រិតអតិបរមានៃការបញ្ចេញ គឺ ៥០០mg/m$^3$។ ចំណែកឯរោងចក្របេតុង គឺ ៥០០ mg/m$^3$។

ទោះជាយ៉ាងណា វិធានការសំខាន់ផ្សេងទៀតដែលជួយកាត់បន្ថយការបំពុលខ្យល់ គឺការកំណត់កម្រិតស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត ដូចជាយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំដែលផលិត និងយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល៥ឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត រួមទាំងចំពោះសារធាតុដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្មដូចជា ស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ូប្រហើរ។

ម្យ៉ាងវិញទៀត ដើម្បីដោះស្រាយ ឬកាត់បន្ថយបញ្ហានៃការបំពុលខ្យល់ដែលបណ្តាលមកពីកាកសំណល់ ផ្សេងៗបានយ៉ាងមានប្រសិទ្ធភាពនោះក៏គួរមានការរួមជាចាំបាច់ពីសំណាក់ប្រជាពលរដ្ឋគ្រប់រូប ដោយពួកគេត្រូវចេះធ្វើការរៀបចំទុកដាក់កាកសំណល់ផ្សេងៗបានត្រឹមត្រូវ ហើយបញ្ឈប់សកម្មភាពដុតសំរាម។

### ២.២.២. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលដោយសំណល់រឹងរាវ និងសំឡេង

#### ២.២.២.១.វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលដោយសំណល់រឹងរាវ

សំណល់មិនថារឹង ឬរាវនោះទេ គឺសុទ្ធតែអាចធ្វើឱ្យបាត់បង់នូវសោភ័ណភាពនៃទីក្រុង ដោយបង្កផលប៉ះពាល់ទៅលើបរិស្ថាន ក៏ដូចជាបញ្ហាសុខភាពផងដែរ។ ដូច្នេះហើយទើបយុទ្ធនាការអប់រំនិងច្បាប់ស្តីពីការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ រួមទាំងអនុក្រឹត្យស្តីពីការត្រួតពិនិត្យលើការបំពុលផ្សេងៗត្រូវបានបង្កើតឡើង។

ជាទូទៅសំណល់ត្រូវបានគេបែងចែកជា ២ ប្រភេទដាច់ពីគ្នា គឺសំណល់រឹង និងសំណល់រាវ។

##### ២.២.២.១.១. សំណល់រឹង

ការគ្រប់គ្រងសំណល់រឹងនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានរៀបចំ និងអនុវត្តបន្ថែមដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ក្នុងនោះបានចែងទាក់ទងទៅនឹងការគ្រប់គ្រងសំរាមពីរប្រភេទ គឺសំណល់រឹងធម្មតា និងសំណល់រឹងប្រកបដោយគ្រោះថ្នាក់។ ហើយការរៀបចំចាត់ចែងសំណល់ទាំង ២ប្រភេទនេះត្រូវស្ថិតក្រោមការសម្រេចរបស់

[98] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ/បក, ៦ កក្កដា ២០០០, មាត្រា៨។

ក្រសួងបរិស្ថានក្នុងការពិនិត្យលើការអនុវត្តន៍រៀបចំបោះចោល ប្រមូល ដឹកជញ្ជូន ស្តុកទុក កែច្នៃ កាត់បន្ថយ និងការចាក់ចោលសំរាម។[99]

ដោយឡែកការកើនឡើងនៃសំណល់រឹង គឺបណ្តាលមកពីកំណើននៃតម្រូវការក្នុងការប្រើប្រាស់របស់មនុស្ស។ ដូច្នេះការកាត់បន្ថយសំណល់រឹងក៏ផ្តើមចេញពីសកម្មភាពរបស់មនុស្សម្នាក់ៗផងដែរ ដោយបញ្ឈប់នូវសកម្មភាពបោះចោល និងដុតសំណល់រឹង ប្រើប្រាស់ផលិតផលដែលមានជាតិប្លាស្ទិក ហើយព្យាយាមកែច្នៃឡើងវិញ និងជាពិសេសយកសំណល់រឹងទៅធ្វើជាជីកំប៉ុសប្រើប្រាស់ក្នុងវិស័យកសិកម្ម។

**រូបទី៣៖ វិធានការទូទៅដោះស្រាយក្នុងការបំពុលដោយសំណល់រឹង**




(ប្រភព ៖ បរិស្ថានសៀវភៅជំនួយស្មារតី)

រូបខាងលើមានវិធានការ ៣ ដែលសំខាន់ និងងាយយកមកអនុវត្តន៍ក្នុងការដោះស្រាយបញ្ហានៃការបំពុលដោយសំណល់រឹង។ កន្លែងចាក់សំណល់ គឺជាវិធីមូលដ្ឋានមួយដែលនៅក្នុងប្រទេសជាច្រើនប្រើប្រាស់សម្រាប់បោះចោលសំណល់រឹងចេញពីទីក្រុង។ វាជាដំណើរការដ៏សាមញ្ញបំផុតមួយ ដោយកាកសំណល់រឹងនឹងត្រូវបានដឹកយកទៅចាក់ចោលនៅកន្លែងចាក់សំណល់ បន្ទាប់មកគេប្រើត្រាក់ទ័រឈូសដីដើម្បីធ្វើការបង្ហាប់ និងចាក់ស្រទាប់ដីពីលើដើម្បីកប់សម្រាម។ រីឯកំណៃច្នៃជាថ្មី ជាការញែករូបធាតុ ឬបំណែកចែកនៃសំណល់រឹងត្រូវបានធ្វើឡើងនៅក្នុងវិធានការកំណៃច្នៃជាថ្មី

[99] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ៣៦អនក្រ/បក, ២៧ មេសា ១៩៩៩, មាត្រា៦។

ដើម្បីដឹងប្រភេទនៃសំណល់រឹងណាដែលអាចយកមកធ្វើការកែច្នៃប្រើប្រាស់ឡើងវិញបានដូចជា លោហៈ កែវ និងក្រដាស ជាដើម។ ចំពោះកំប៉ុសសកម្មវិញ ទាក់ទងទៅនឹងការញែកនូវសំណល់សរីរាង្គ (សំណល់អាហារ ក្រដាស រុក្ខជាតិ ) ចេញពីសំណល់អសរីរាង្គ ហើយសំណល់សរីរាង្គទាំងនោះត្រូវបានទុករហូតដល់បំបែកទៅជាផលិតផលសរីរាង្គសំរេច ឬ បំលែងទៅជាជីសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម។

### ២.២.២.១.២ សំណល់រាវ

ការហាមឃាត់ដាច់ខាតចំពោះការចាក់ចោល ការបង្ហូរចេញសំណល់រាវពីរាល់ប្រភពបំពុលដែលមិនបានអនុវត្តតាមកម្រិតស្តង់ដារនៃការបញ្ចេញសំណល់រាវ គឺជាវិធានការមួយកាត់បន្ថយក្នុងការបំពុលដោយសំណល់រាវ។[100] ម្យ៉ាងទៀតដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះនៅមុនពេលធ្វើការបញ្ចេញនូវសំណល់រាវពីប្រភពបំពុលនានាចូលតំបន់ទឹកសាធារណៈនោះ គឺត្រូវមានការអនុញ្ញាតសិន ហើយក្រសួងបរិស្ថានជាស្ថាប័នដែលត្រូវរៀបចំកម្រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ។[101]

ចំពោះផែនការយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានក្នុងការគ្រប់គ្រងសំណល់ទាំងរឹងទាំងរាវ គឺមានការរៀបចំគោលនយោបាយជាតិសម្រាប់ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន រួមជាមួយផែនការមេស្តីពីវិធានការចម្រុះនូវការគ្រប់គ្រងសំណល់រឹងប្រកបដោយនិរន្តភាព។ ក្នុងនោះដែរ ក្រសួងបរិស្ថានក៏ព្យាយាមពង្រឹងទៅលើការអនុវត្តច្បាប់ លើកកម្ពស់ការអនុវត្តន៍កម្មវិធីកែច្នៃ និងការប្រើប្រាស់ឡើងវិញនៃសំណល់ បង្កើតកម្មវិធីកាត់បន្ថយបរិមាណសំណល់ និងបង្កើតទីលានចាក់សំណល់ប្រកបដោយបច្ចេកទេស ហើយមានអនាម័យ។[102]

### ២.២.២.២. វិធានការគតិយុត្តដោះស្រាយចំពោះការបំពុលដោយសំឡេង

ដើម្បីកាត់បន្ថយនូវសកម្មភាពបង្កជាការបំពុលដោយសំឡេងនោះ ការអប់រំ និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងពីបញ្ហានៃផលប៉ះពាល់ និងការកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញសំឡេង គឺជាវិធានការដ៏សំខាន់។ ការបញ្ចេញសំឡេងពីប្រភពនានាដូចជា យានយន្ត ទីតាំងផលិតកម្ម រោងចក្រ សហគ្រាស ទីកន្លែងផ្សេងៗ ឬតាមលំនៅដ្ឋានដែលបង្កឱ្យមានការបំពុលសំឡេង គឺត្រូវហាមឃាត់ឱ្យបានដាច់ខាត។ ការកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញសំឡេងពី

---

[100] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩, មាត្រា៦។

[101] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩, មាត្រា៧។

[102] ចូលមើលលើកចុងក្រោយ ៣០ ឧសភា ២០១៨, http://www.healthcambodia.com/p7901/។

ប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតស្តង់ដារសំឡេងជាអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន ក៏ត្រូវធ្វើឡើងផងដែរ។[103]

## សេចក្តីសន្និដ្ឋាន

ការរៀបចំនូវខណ្ឌ គឺជាកត្តាសំខាន់ដើម្បីសម្រេចបាននូវទិសដៅនៃភាពជោគជ័យរបស់ការរៀបចំក្រុងឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អ។ ការធានាបាននូវសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌចំការមន គឺមានលក្ខណៈសំខាន់ណាស់ដើម្បីឲ្យការរៀបចំក្រុង និងការរស់នៅរបស់ប្រជាជនក្នុងតំបន់នេះមានភាពល្អប្រសើរស្របតាមលក្ខណៈស្តង់ដារ។ ដោយឡែកទោះបីជា

[103] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ/បក, ៦ កក្កដា ២០០០, មាត្រា៧។

មានការអភិវឌ្ឍន៍ក៏ពិតមែន ប៉ុន្តែភាពខ្វះចន្លោះនៅតែមាន គឺថ្មីត្បិតតែខណ្ឌចំការមនបានធ្វើការរៀបចំហេដ្ឋារចនាសម្ព័ន្ធបានច្រើនដូចជាការរៀបចំឲ្យមាននូវផ្លូវថ្នល់ លូ បង្គោលភ្លើងបំភ្លឺតាមផ្លូវ ប៉ុន្តែខណ្ឌនេះបាននឹងកំពុងជួបប្រទះនូវបញ្ហាសណ្តាប់ធ្នាប់ និងសោភ័ណភាព។

ដើម្បីធានាបាននូវការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌនេះ ការស្វែងយល់អំពីបុព្វហេតុដែលនាំឲ្យមានការរៀបចំខណ្ឌដែលមានដូចជា កំណើនប្រជាជន ចរាចរណ៍ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ បានចោទជាបញ្ហាចំបងដែលបណ្តាលឲ្យមានការរៀបចំឡើង។ ជាពិសេសការរៀបចំតាមដងផ្លូវដែលបច្ចុប្បន្ននេះបញ្ហានៃការលក់ដូរតាមដងផ្លូវសាធារណៈរបស់អាជីវករមួយចំនួនបានធ្វើឲ្យប៉ះពាល់ទៅដល់ការរៀបចំសណ្តាប់ធ្នាប់យ៉ាងខ្លាំង។ រីឯបញ្ហានៃការបំពុលបរិស្ថានវិញ គឺធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសោភ័ណភាពក្នុងខណ្ឌនេះ។

ក្រៅពីការសិក្សាទៅលើហេដ្ឋារចនាសម្ព័ន្ធ ការស្វែងយល់ពីបញ្ហាបរិស្ថាននៅក្នុងតំបន់នេះក៏ជាកត្តាដ៏ចំបងមួយដែលជួយសម្រួលដល់ការរៀបចំបរិស្ថានឲ្យមានគុណភាពសមស្របសម្រាប់ការរស់នៅ និងសោភ័ណភាពល្អផងដែរ។ បញ្ហាបរិស្ថានចំបងជារួមក្នុងខណ្ឌមានដូចជា បញ្ហានៃការបំពុលទឹក ការបំពុលដី ការបំពុលខ្យល់ រួមទាំងបញ្ហាបំពុលដោយសំណល់រឹង រាវ និងសំឡេងដែលកើតចេញពីច្រើនប្រភពបានធ្វើឲ្យគុណភាពនៃការរស់នៅក្នុងខណ្ឌនេះធ្លាក់ចុះ។ ទោះជាយ៉ាងណា វិធានការដោះស្រាយនានាក៏បានភ្ជាប់មកជាមួយនឹងបញ្ហាទាំងនោះដែលជាគន្លឹះក្នុងការបង្កើនគុណភាពនៃបរិស្ថានដើម្បីរក្សាបាននូវសោភ័ណភាពល្អប្រសើរ។ លើសពីនេះទៅទៀត ប្រសិនបើមានការចូលរួមសហការគ្នារវាងរាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរ ក្រសួង ឬរាល់ស្ថាប័នពាក់ព័ន្ធ រួមទាំងប្រជាពលរដ្ឋនោះ ការរៀបចំសណ្តាប់ធ្នាប់ ព្រមទាំងសោភ័ណភាពក្នុងខណ្ឌនឹងទទួលបានជោគជ័យទាំងស្រុងជាក់ជាមិនខាន៕

## អនុសាសន៍

ទោះបីជាមានការអភិវឌ្ឍច្រើននៅក្នុងខណ្ឌចំការមននេះក៏ពិតមែន ប៉ុន្តែក៏នៅតែមានបញ្ហាចោទមួយចំនួនដែលប្រជាពលរដ្ឋចង់ឲ្យអាជ្ញាធរធ្វើការកែសម្រួលរួមមានដូចជាបញ្ហា ផ្លូវថ្នល់ ប្រព័ន្ធលូ ការលក់ដូរគ្មានសណ្តាប់ធ្នាប់តាមដងផ្លូវ អសន្តិសុខ និងភាពអសណ្តាប់ធ្នាប់ផ្សេងៗ។ រីឯបញ្ហាដ៏គួរឲ្យព្រួយបារម្ភមួយទៀតនោះ គឺបញ្ហានៃការគ្រប់គ្រងកាកសំណល់មិនបានត្រឹមត្រូវដែល

បង្កការបំពុលដល់បរិស្ថាន ហើយធ្វើឲ្យមានការកកស្ទះប្រព័ន្ធលូ ប៉ះពាល់ដល់សោភ័ណភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខណ្ឌ។

រាជរដ្ឋាភិបាលកម្ពុជាគួរធ្វើការអភិវឌ្ឍបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធលូសាធារណៈឲ្យមានលក្ខណៈកាន់តែប្រសើរ ក៏ព្រោះផ្លូវមួយចំនួនក្នុងខណ្ឌ គឺមានសភាពតូចចង្អៀតនៅឡើយដែលបណ្តាលឲ្យមានការកកស្ទះចរាចរណ៍ស្ទើររៀងរាល់ថ្ងៃ រីឯបញ្ហាស្ទះលូវិញគឺជាបញ្ហាប្រឈមដែលមិនគួរមើលរំលង ដោយបញ្ហានេះកើតមានឡើងមិនមែនតែនៅក្នុងខណ្ឌចំការមនប៉ុណ្ណោះទេ ប៉ុន្តែក្នុងរាជធានីភ្នំពេញទាំងមូលផ្ទាល់តែម្តង។ ក្នុងនោះដែរ អាជ្ញាធរដែលពាក់ព័ន្ធទាំងអស់ សូមជួយយកចិត្តទុកដាក់ឲ្យបានខ្ពស់ ក៏ដូចជាចូលរួមក្នុងការស្វែងរកនូវវិធានការដែលមានប្រសិទ្ធិភាព ដើម្បីដោះស្រាយបញ្ហានៃការបំពុលបរិស្ថានដែលបណ្តាលឲ្យបាត់បង់សោភ័ណភាពក្នុងខណ្ឌ និងត្រួតពិនិត្យទៅបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ បន្ថែមផង។ លើសពីនេះទៅទៀត ក៏គួរធ្វើការរឹតបន្តឹងនូវការអនុវត្តច្បាប់ដោយពិន័យ ចំពោះរាល់សកម្មភាពល្មើសណាដែលបំផ្លាញដល់បរិស្ថាន។ ចំពោះប្រជាពលរដ្ឋ និង ភ្នាក់ងារមានសមត្ថកិច្ចដែលរស់នៅក្នុងតំបន់សូមចូលរួមក្នុងការថែរក្សាការពារបរិស្ថាន និងសណ្តាប់ធ្នាប់ ដើម្បីផ្តល់ភាពកាន់តែល្អប្រសើរឡើងចំពោះសោភ័ណភាពក្នុងខណ្ឌ។ ការស្វែងយល់អំពីបរិស្ថាន គឺជាកត្តាសំខាន់ក្នុងការរក្សាបាននូវបរិស្ថានល្អ ដូច្នេះសូមអំពាវនាវទៅដល់គណៈដឹកនាំទាំងអស់ ដែលពាក់ព័ន្ធចូលរួមក្នុងការបង្កើតជាវេទិកាអប់រំណែនាំដល់ប្រជាពលរដ្ឋ ហើយព្យាយាមធ្វើការផ្សព្វផ្សាយឲ្យពួកគេបានយល់អំពីសារៈសំខាន់នៃបរិស្ថាន ក៏ដូចជាចាប់អារម្មណ៍លើផលប៉ះពាល់នៃការបំពុល៕

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២២ ឧសភា ២០០៨។

ច្បាប់ស្តីពីផ្លូវថ្នល់, លេខ នស/រកម/០៥១៤/០០៨, ០៤ ឧសភា ២០១៤។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ នស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦។

ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រសិប្បកម្ម, លេខ នស/រកម/០៦០៦/០១៨, ២៣ ឧសភា២០០៦។

ច្បាប់ស្តីពីការវិសោធនកម្មច្បាប់ការគ្រប់គ្រងរោងចក្រសិប្បកម្ម, លេខ នស/រកម/១០១៤/០២៥, ២៣ តុលា ២០១៤។

អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧។

អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥អនក្រ/បក, ២៥ ធ្នូ ២០១៧។

អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ៣៦អនក្រ/បក, ២៧ មេសា ១៩៩៩។

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧អនក្រ/បក, ៦ មេសា ១៩៩៩។

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង, លេខ៤២អនក្រ/បក, ១០ កក្កដា ២០០០។

សេចក្តីណែនាំស្តីពីការប្រើប្រាស់ផ្លូវថ្នល់, លេខ០១៥ផថ, ២០ មករា ២០០៤។


## សៀវភៅ និងឯកសារផ្សេងទៀត


ខណ្ឌចំការមន. កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន. ឆ្នាំ ២០១៨-២០២០។

ខណ្ឌចំការមន. ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខណ្ឌចំការមន. ឆ្នាំ២០១៥-២០១៩។

ជួន ណាត. *វចនានុក្រមខ្មែរ* . ភ្នំពេញ៖ ១៩៦៧។

ឈុន ពហុ, *ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប)* . ភ្នំពេញ, ២០០៤។

ណូអែល អូប្រាយែន. *បរិស្ថានសៀវភៅជំនួយស្មារតី.* កែសម្រួល ទិន ពន្លក. ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៥។

ចេង ច័ន្ទសង្ហារ. *នីតិរដ្ឋបាលទូទៅ.* រៀបរៀងដោយ ជួប បិតបេរឬទ្ធិ. ភ្នំពេញ៖ ២០១២-២០១៣។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ. *សៀវភៅអប់រំបំណិតជីវិតស្តីពីបរិស្ថាន.* ព្រះរាជាណាចក្រកម្ពុជា ៖ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា៖ ២០១៣។

វ៉ាន់ឌី កាអុន. *សុបិន និងការពិត.* ភាគ២. ភ្នំពេញ៖ សមាគមកម្ពុជា-អាស៊ី, ២០១២។

អ៊ុន សកក្កដា. *"នីតិនគរូបនីយវិទ្យា".* សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២។

របាយការណ៍ប្រចាំឆមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន. លេខ ៨៥/១៨ របក. ភ្នំពេញ៖២០១៨។

ព្រឹត្តិបត្ររដ្ឋបាលរាជធានីភ្នំពេញលេខ១៨ ខែមេសា ឆ្នាំ២០១៦។

## គេហទំព័រ

គេហទំព័រ https://theculturetrip.com/middle-east/lebanon/articles/the-10-oldest-cities-in-the-world/

គេហទំព័រ http://islamic-arts.org/2011/damascus-history-arts-and-architecture/

គេហទំព័រ http://phnompenh.gov.kh/phnom-penh-city/history

គេហទំព័រ https://www.slideshare.net/khmer-sacrifice/1975-1979

គេហទំព័រ https://www.rfa.org/khmer/multimedia/after-khmer-rouge-11092017202904.html

គេហទំព័រ http://phnompenh.gov.kh/phnom-penh-city/facts/

គេហទំព័រ http://www.worldometers.info/world-population/cambodia-population/

គេហទំព័រ https://postnews.com.kh/hotnews/120869

គេហទំព័រ https://opendevelopmentcambodia.net/km/topics/pollution-and-waste/#ref-74643-2

គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/

គេហទំព័រ http://www.healthcambodia.com/p6241/

គេហទំព័រ https://www.conserve-energy-future.com/causes-effects-solutions-of-land-pollution.php

គេហទំព័រ https://www.rfa.org/khmer/program/health/Health-effects-people-use-dirty-water-12152016033054.html

គេហទំព័រ https://audiopse.blogspot.com/2017/02/blog-post_25.html?m=1

គេហទំព័រ https://urbanvoicecambodia.net/maps/reports/view/9749

គេហទំព័រ http://www.un.org

គេហទំព័រ http://www.healthcambodia.com/p9670/

គេហទំព័រ http://www.healthcambodia.com/p9842/

គេហទំព័រ http://www.healthcambodia.com/p7901